ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រក្រសួងផែនការ
# ២០១៤-២០១៨

ក្រសួងផែនការ

ខែមករា ឆ្នាំ២០១៤

# អារម្ភកថា

កម្ពុជា បានចាប់ផ្តើមអភិវឌ្ឍប្រទេសពេញលេញពីឆ្នាំ១៩៩៨ នៅពេលដែលសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ហើយប្រទេសទទួលបានសន្តិភាព ដែលធ្វើឲ្យកម្ពុជាមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស និងជីវភាព ប្រជាជនកាន់តែមានភាពប្រសើរឡើងជាលំដាប់។ នៅក្នុងរបបសេដ្ឋកិច្ចទីផ្សារមិនអាចខ្វះបានទេនូវផែនការសេដ្ឋកិច្ចសម្រាប់តម្រង់ទិសអភិវឌ្ឍន៍ និងកំណត់អាទិភាពលើវិស័យនានា។ រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិកាលទី៥ នៃរដ្ឋសភានេះ បានកំណត់កំណត់គោលនយោបាយអាទិភាព របស់ខ្លួននៅក្នុង ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣*** ដែលនឹងត្រូវអនុវត្តដោយ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៤-២០១៨***។

ដើម្បីរួមចំណែកអនុវត្ត*ផ.យ.អ.ជ. ២០១៤-២០១៨* ក៏ដូចជា គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងផែនការក៏បានរៀបចំ *ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផ.យ.ផ.ក.) ២០១៤-២០១៨* ដែលត្រូវបន្តពីអាណត្តិកាលផែនការមុនរបស់ក្រសួងផែនការ គឺ*ផ.យ.ផ.ក. បច្ចុប្បន្នកម្ម ២០០៩-២០១៣*។ផែនការនេះ នឹងធ្វើជាឧបករណ៍បង្ហាញទិសសម្រាប់ការអនុវត្តសកម្មភាពនានារបស់អគ្គនាយកដ្ឋាននិងនាយកដ្ឋាននានាក្នុងក្រសួងផែនការ និងជាផែនទីបង្ហាញទិសដល់ដៃគូអភិវឌ្ឍនានា ដែលមានគោលបំណងសហការ និងគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រសួងផែនការ។

ផែនការនេះចែកជាបួនផ្នែកសំខាន់គឺ ផ្នែកទី១ បង្ហាញពីរចនាសម្ព័ន្ធនិងបេសកកម្ម របស់ក្រសួងផែនការ ដែលបង្ហាញសំខាន់ពីបេសកកម្មរបស់អគ្គនាយកដ្ឋានទាំងពីរ។ ផ្នែកទី២ បង្ហាញពីលទ្ធផលនៃការនៃការអនុវត្ត*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣* ផ្នែកទី៣ *ផ.យ.ផ.ក.២០១៤-២០១៨* ដែលជាទិសដៅការងាររបស់ក្រសួងផែនការ សម្រាប់អនុវត្តនិងសម្រេចឲ្យបាន នៅក្នុងអំឡុងពេលពីឆ្នាំ២០១៤-២០១៨។ ផ្នែកទី៤ គឺជា*ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤ របស់ក្រសួងផែនការ*ដែលជាផែនការប្រចាំឆ្នាំកំណត់នូវបណ្តាសកម្មភាពលម្អិតនានា ក្នុងទិសដៅការងារនីមួយៗ។ ផែនការប្រតិបត្តិនេះ នឹងត្រូវរៀបចំធ្វើជារៀងរាល់ឆ្នាំ រហូតដល់ចប់អាណត្តិកាលនៃផែនការ។

ខ្ញុំសូមថ្លែងអំណរគុណ ចំពោះឯកឧត្តមអគ្គនាយកផែនការ និងលោកជំទាវអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានសហការគ្នារៀបចំផែនការនេះ។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណ ដល់ដៃគូអភិវឌ្ឍនានា ជាពិសេស UNFPA និង UNICEF ដែលសហការគាំទ្រដល់ដំណើរការរៀបចំផែនការនេះ។ ខ្ញុំសង្ឃឹមថា ផែនការនេះ នឹងជួយតម្រង់ទិសការងារដល់អង្គភាពនានារបស់ក្រសួងផែនការ និងផ្តល់ការណែនាំ ដល់ដៃគូអភិវឌ្ឍនានា ដែលមានគោលបំណងសហការនឹងគាំទ្រដល់ក្រសួងផែនការងារ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

# តារាងមាតិកា


**អារម្ភកថា** ........................................ i

**តារាងមាតិកា** ........................................ ii

**ផ្នែកទី១៖ រចនាសម្ព័ន្ធនិងបេសកកម្មរបស់ក្រសួងផែនការ** ........................................ ១

I. រចនាសម្ព័ន្ធ ........................................ ១

II. បេសកកម្ម ........................................ ១

២.១ បេសកកម្មរបស់អគ្គនាយកដ្ឋានផែនការ ........................................ ១

២.២ បេសកកម្មរបស់វិទ្យាស្ថានជាតិស្ថិតិ ........................................ ៣

**ផ្នែកទី២៖ វឌ្ឍនភាពនៃការអនុវត្ត ផែនការយុទ្ធសាស្ត្រក្រសួងផែនការ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ........................................ ៥

I. សេចក្តីផ្តើម ........................................ ៥

II. វឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ ........................................ ៥

២.១ សមិទ្ធផលសំខាន់ៗ ដែលអគ្គនាយកដ្ឋានផែនការ សម្រេចបាន ........................................ ៥

២.២ សមិទ្ធផលសំខាន់ៗ ដែលវិទ្យាស្ថានជាតិស្ថិតិតសម្រេចបាន ........................................ ១២

២.៣ សមិទ្ធផលសំខាន់ៗ ដែលអគ្គនាយកដ្ឋានផែនការនិងវិទ្យាស្ថានជាតិស្ថិតិរួមគ្នាសម្រេចបាន ........................................ ១៥

**ផ្នែកទី៣៖ ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផ.យ.ផ.ក.) ២០១៤-២០១៨** ........................................ ១៨

I. ប្រវត្តិដើម ........................................ ១៨

II. សមាសភាពសំខាន់ៗ សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធី ........................................ ១៨

២.១ សម្រាប់អគ្គនាយកដ្ឋានផែនការ ........................................ ១៨

២.២ សម្រាប់វិទ្យាស្ថានជាតិស្ថិតិ ........................................ ២០

២.៣ ការងាររួមរបស់អគ្គនាយកដ្ឋានផែនការនិងវិទ្យាស្ថានជាតិស្ថិតិ ........................................ ២៣

III. តារាងម៉ាទ្រីស *ផ.យ.ផ.ក. ២០១៤-២០១៨*........................................ ២៥

តារាងម៉ាទ្រីស *ផ.យ.ផ.ក. ២០១៤-២០១៨* ទី១៖ អគ្គនាយកដ្ឋានផែនការ ........................................ ២៥

តារាងម៉ាទ្រីស *ផ.យ.ផ.ក. ២០១៤-២០១៨* ទី២៖ វិទ្យាស្ថានជាតិស្ថិតិ ........................................ ៣៥

តារាងម៉ាទ្រីស *ផ.យ.ផ.ក. ២០១៤-២០១៨* ទី៣៖ ការងាររួម ........................................ ៤០

**ផ្នែកទី៤÷ ផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៤ របស់ក្រសួងផែនការ** ..................................... ៤៣
I. សកម្មភាពអាទិភាពសំខាន់ៗ របស់អគ្គនាយកដ្ឋានផែនការ សម្រាប់ឆ្នាំ២០១៤ .......... ៤៣
II. សកម្មភាពអាទិភាពសំខាន់ៗ របស់វិទ្យាស្ថានជាតិស្ថិតិ សម្រាប់ឆ្នាំ២០១៤ .................. ៤៥
III. សកម្មភាពអាទិភាពសំខាន់ៗដែលអគ្គនាយកដ្ឋានផែនការនិងវិទ្យាស្ថានជាតិស្ថិតិរួមគ្នា សម្រាប់ឆ្នាំ២០១៤ ........................................................................................ ៤៧
IV. តារាងម៉ាទ្រីសផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤ របស់ក្រសួងផែនការ .......................... ៤៩
តារាងម៉ាទ្រីសផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤ ទី១៖ អគ្គនាយកដ្ឋានផែនការ ........... ៤៩
តារាងម៉ាទ្រីសផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤ ទី២៖ វិទ្យាស្ថានជាតិស្ថិតិ ................. ៦៥
តារាងម៉ាទ្រីសផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤ ទី៣៖ ការងាររួម ................................ ៧៩
**ឧបសម្ព័ន្ធ ១÷ អង្គការលេខរបស់ក្រសួងផែនការ** ................................................................. ៨៥
**ឧបសម្ព័ន្ធ ២÷ អនុក្រឹត្យលេខ៥៥ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងផែនការ** ................................................................................ ៨៦
**ឧបសម្ព័ន្ធ ៣÷ អនុក្រឹត្យលេខ ៨៥ អនក្រ.បក. ការបង្កើតនាយកដ្ឋានមួយចំនួន ចំណុះ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ** ........................................................ ៩៧
**ឧបសម្ព័ន្ធ ៤÷ ពាក្យបំព្រួញ** ................................................................................ ១០៣

# ផ្នែកទី១

# រចនាសម្ព័ន្ធនិងបេសកកម្មរបស់ក្រសួងផែនការ

## I. រចនាសម្ព័ន្ធ

រចនាសម្ព័ន្ធនិងតួនាទីរបស់ក្រសួងផែនការ ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ៥៥ អនប្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពី ការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងផែនការ។ ផ្អែកតាមអនុក្រឹត្យនេះ ក្រសួងផែនការរួមមាន អគ្គនាយកដ្ឋាន និងអង្គភាពមានឋានៈស្មើអគ្គនាយកដ្ឋានចំនួន៣ គឺៈ

- អគ្គនាយកដ្ឋានផែនការ (អនផក)
- វិទ្យាស្ថានជាតិស្ថិតិ (វជស) និង
- អគ្គាធិការដ្ឋាន។

ក្រៅពីអង្គភាពទាំងបីក្រសួងផែនការក៏មាននាយកដ្ឋានចំនួន ៤ ទៀត ដែលមិនស្ថិតក្រោមឱវាទអគ្គនាយកដ្ឋានទាំងបីគឺ ស្ថិតក្រោមឱវាទផ្ទាល់របស់ថ្នាក់ដឹកនាំក្រសួង។ អង្គភាពទាំងនេះ រួមមានៈ

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានរដ្ឋបាលទូទៅ
- នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ និង
- នាយកដ្ឋានសវនកម្ម

នៅចុងឆ្នាំ២០១៣ ដែលជាដើមអាណត្តិកាលរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់អាណត្តិកាលទី៥នៃរដ្ឋសភា អគ្គលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍ ត្រូវបានផ្ទេរពីទីស្តីការគណៈរដ្ឋមន្ត្រី មកក្រសួងផែនការ ដែលមាន ៤នាយកដ្ឋានចំណុះគឺៈ នាយកដ្ឋានផ្សព្វផ្សាយនិងព័ត៌មាន នាយកដ្ឋានបណ្តុះបណ្តាលនិងការអភិវឌ្ឍ និង នាយកដ្ឋានវិភាគគោលនយោបាយប្រជាជន និង នាយកដ្ឋានអភិវឌ្ឍសហគមន៍ ។

## II. បេសកកម្ម

*ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផ.យ.ផ.ក.) ២០១៤-២០១៨* នឹងបង្ហាញតែពីបេសកកម្មសំខាន់ៗរបស់អគ្គនាយកដ្ឋានផែនការ និងវិទ្យាស្ថានជាតិស្ថិតិ ដែលជាអង្គភាពទទួលខុសត្រូវហើយអនុវត្តនូវតួនាទីបច្ចេកទេស សំខាន់ពីរ។ បេសកកម្មរបស់ផ្នែកទាំងពីរនៃក្រសួងផែនការរួមមានៈ

## ២.១ បេសកកម្មរបស់អគ្គនាយកដ្ឋានផែនការ

១. ដឹកនាំ និងសម្របសម្រួលរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការកម្រិតជាតិ ដោយរួមទាំងការរៀបចំ*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.)* ដែលជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានចែងក្នុង *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣*ដើម្បីឈានទៅសម្រេចបានស្ថិរភាពកំណើនសេដ្ឋកិច្ចខ្ពស់ សម្រេចឲ្យបានគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា និងការកាត់បន្ថយភាពក្រីក្រ។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានផែនការ ក្នុងនាមក្រសួងផែនការ មានតួនាទីសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា ធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃ វឌ្ឍនភាពនៃការអនុវត្ត *ផ.យ.អ.ជ.* តាមរយៈការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ និងរបាយការណ៍ពាក់កណ្តាលអាណត្តិ។

២. ផ្តល់ការណែនាំ និងការគាំទ្រផ្នែកបច្ចេកទេស ដល់ក្រសួង ស្ថាប័ននានា ដើម្បី៖

- ធានាថាព័ត៌មាននានាពាក់ព័ន្ធនឹងផែនការ ដែលក្រសួង ស្ថាប័ននានាផ្តល់មកក្រសួងផែនការត្រូវផ្អែកលើយុទ្ធសាស្ត្រដែលបានឯកភាពគ្នាក្នុងវិស័យ សម្រាប់អនុវត្តគោលនយោបាយអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣។
- ធានាឲ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព រវាងដំណើរការរៀបចំផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ដៃគូអភិវឌ្ឍន៍។
- ធានាថា ការរៀបចំផែនការរបស់ក្រសួង ស្ថាប័ននានា នៅថ្នាក់ជាតិ ត្រូវបាកបញ្ចូលនូវគំនិតផ្តួចផ្តើមផែនការរបស់ថ្នាក់ជាតិ នៅក្នុងវិស័យរបស់ខ្លួន។
- ធានាថា គ្រប់ភាគីដែលមានចំណែកពាក់ព័ន្ធទាំងអស់ (រួមទាំង អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងសង្គមស៊ីវិល តាមរយៈយន្តការផ្សេងៗ) មានឱកាសក្នុងការរួមចំណែករៀបចំជាតុចូល ជាមួយក្រសួង ស្ថាប័ននានា នៅក្នុងដំណើរការរៀបចំជាតុចូល និងផ្តល់មកក្រសួងផែនការ សម្រាប់រៀបចំ *ផ.យ.អ.ជ.* និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ពីវឌ្ឍនភាពនៃការអនុវត្ត *ផ.យ.អ.ជ.*។

៣. រៀបចំនិងអនុវត្ត កម្មវិធីនិងគម្រោងនានា ដើម្បីអនុវត្តតួនាទីដែលត្រូវបានកំណត់សម្រាប់ ក្រសួងផែនការ (អគ្គនាយកដ្ឋានផែនការ) ដើម្បីគាំទ្រដល់សកម្មភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជា សកម្មភាពកាត់បន្ថយភាពក្រីក្រ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ កម្មវិធីអាហារូបត្ថម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា គោលនយោបាយជាតិប្រជាជន គោលនយោបាយសមភាពយេនឌ័រ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍។ល។ ព្រមទាំង រៀបចំរបាយការណ៍ដើម្បីឆ្លើយតបនឹងការទទួលខុសត្រូវរបស់កម្ពុជា ពាក់ព័ន្ធនឹងអនុសញ្ញា

ផ្សេងៗ និងតំណាងឲ្យរាជរដ្ឋាភិបាលកម្ពុជាឬក្រសួងផែនការ នៅក្នុងពិធីផ្សេងៗ នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។

## ២.២ បេសកកម្មរបស់វិទ្យាស្ថានជាតិស្ថិតិ

ស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីស្ថិតិ ក៏ដូចជាអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិមានភារកិច្ចទទួលខុសត្រូវក្នុងការ ៖

១. ប្រមូល កែឆ្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិតាមការធ្វើជំរឿន អង្កេត និងប្រើប្រាស់ប្រភពទិន្នន័យរដ្ឋបាល

២.ចងក្រងគណនេយ្យជាតិកម្ពុជា និងសន្ទស្សន៍ថ្លៃ ក៏ដូចជាសូចនាករសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រ

៣. ធ្វើការសម្របសម្រួលក្នុងសកម្មភាពនៃកិច្ចអភិវឌ្ឍន៍ស្ថិតិ រួមនឹងការបណ្តុះបណ្តាលជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងផ្នែកឯកជន ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន

៤. ធ្វើកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពស្ថិតិជាមួយអង្គការអន្តរជាតិ ស្ថាប័នស្ថិតិនៃប្រទេសនានា និងផ្នែកឯកជននានាទៅតាមបទបញ្ញត្តិច្បាប់ជាធរមាន

៥. កំណត់ស្តង់ដារស្ថិតិដែលទាក់ទងនឹងចំណាត់ថ្នាក់ ទស្សនទាន និយមន័យ និងអង្គពិនិត្យពិចារណាស្ថិតិ ដើម្បីចៀសវាងការភ័ន្តច្រឡំពីសំណាក់អ្នកប្រើប្រាស់ទិន្នន័យ និងភាពជាន់គ្នាក្នុងការផលិតស្ថិតិជាតិ។

ចក្ខុវិស័យត្រូវបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ២០០២-២០០៦ និងផែនការមេស្ថិតិ ២០០៨-២០១៥ដោយឈរលើមូលដ្ឋាននៃគោលការណ៍៥ចំណុច៖ *ភាពសំខាន់ភាពសុចរិត ភាពអាចប្រើប្រាស់បាន វិជ្ជាជីវៈនិយម និងជំនឿទុកចិត្ត។*

*តាមរយៈនេះ វិទ្យាស្ថានជាតិស្ថិតិមានបេសកកម្មក្នុងការសម្របសម្រួល ប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយស្ថិតិផ្លូវការដែលមានគុណភាពខ្ពស់ ដើម្បីជួយដល់ការធ្វើការសម្រេចចិត្ត ការជជែកវែកញែក និងការពិភាក្សានៅក្នុងរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ខេត្តនិងឃុំ ផ្នែកឯកជន និងប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ។*

កម្មវត្ថុមាន ៧ ៖

១. សម្របសម្រួល និងធ្វើឱ្យប្រសើរនូវប្រព័ន្ធស្ថិតិជាតិនៃព្រះរាជាណាចក្រកម្ពុជា

២. វិទ្យាស្ថានជាតិស្ថិតិផ្តល់សេវាកម្មស្ថិតិ ទាន់ពេលវេលាមានការពាក់ព័ន្ធមានការឆ្លើយតប និងគោរពគោលការណ៍សុចរិតភាព និងគុណភាព

៣. ផ្តល់ព័ត៌មាន និងបង្កើនការប្រើប្រាស់ស្ថិតិផ្លូវការ

៤. ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពស្ថិតិអន្តរជាតិ ដែលជាការចាំបាច់ និងមានសារៈសំខាន់សម្រាប់ព្រះរាជាណាចក្រកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍

៥. ស្ថាប័នដែលលើកទឹកចិត្តដល់ការសិក្សាស្វែងយល់ ការច្នៃប្រឌិត និងការអនុវត្តកម្រិតខ្ពស់នៅក្នុងសកម្មភាព និងការអភិវឌ្ឍស្ថិតិ

៦. មានជំនឿទុកចិត្ត និងកិច្ចសហប្រតិបត្តិការ ក្នុងការផ្តល់ទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ

៧. មានការទទួលស្គាល់កម្រិតខ្ពស់ និងគាំទ្រចំពោះវិទ្យាស្ថានជាតិស្ថិតិ ពីសំណាក់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងសហគមន៍។

# ផ្នែកទី២

# វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផ.យ.ផ.ក.) បច្ចុប្បន្នកម្ម ២០០៩-២០១៣

## I. សេចក្តីផ្តើម

*ផែនការយុទ្ធសាស្ត្រក្រសួងផែនការ(ផ.យ.ផ.ក.) បច្ចុប្បន្នកម្ម ២០០៩-២០១៣* គឺជាផែនការលើកទី២ របស់ក្រសួងផែនការ ដែលត្រូវបានធ្វើបច្ចុប្បន្នភាព ពី ផ.យ.ផ.ក. ២០០៦-២០១០ ដើម្បីបន្សុីអាណត្តិកាល ឲ្យត្រូវគ្នានឹងអាណត្តិកាលរបស់រាជរដ្ឋាភិបាលកម្ពុជា និងឯកសារនានាដែលមានលក្ខណៈគោលនយោបាយ និងផែនការ របស់រាជរដ្ឋាភិបាល ដែលត្រូវបានកំណត់នៅក្នុង ផ.យ.អ.ជ. ២០០៦-២០១០។ ផែនការនេះក៏ត្រូវបានរៀបចំឡើងដើម្បីរួមចំណែកអនុវត្ត *ផ.យ.ផ.ក. បច្ចុប្បន្នកម្ម ២០០៩-២០១៣* និងរួមចំណែកធ្វើឲ្យសម្រេចបាន*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.)*។ ផែនការនេះត្រូវបានរៀបចំឡើង ដោយបានកំណត់ទិសដៅនូវទិសដៅការងារសំខាន់របស់អគ្គនាយកដ្ឋានផែនការ និងវិទ្យាស្ថានជាតិស្ថិតិ ដែលត្រូវបានគាំទ្រទាំងហិរញ្ញវត្ថុនិងបច្ចេកទេសដោយដៃគូអភិវឌ្ឍន៍នានា។ ទិសដៅការងារមួយចំនួនមិនស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងដោយក្រសួងផែនការ ដូចនេះសកម្មភាពខ្លះ មិនត្រូវបានមានការយឺតយ៉ាវ មិនអាសម្រេចបានតាមកាលកំណត់ទេ។ ចំណែកសកម្មភាពមួយចំនួនទៀត មិនត្រូវបានអនុវត្តពេញលេញទេ ដោយមូលហេតុខ្វះខាតថវិកាគាំទ្រ។ វឌ្ឍនភាពនៃការអនុវត្ត*ផ.យ.ផ.ក. បច្ចុប្បន្នកម្ម ២០០៩-២០១៣* មានរៀបរាប់នៅក្នុងផ្នែកខាងក្រោម។

## II. វឌ្ឍនភាពនៃការអនុវត្ត *ផ.យ.ផ.ក.បច្ចុប្បន្នកម្ម ២០០៩-២០១៣*

### ២.១ សមិទ្ធផលសំខាន់ៗ ដែលអគ្គនាយកដ្ឋានផែនការសម្រេចបាន

ទិសដៅការងារចំនួន៤ ត្រូវបានលើកឡើងក្នុង *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* សម្រាប់អគ្គនាយកដ្ឋានផែនការអនុវត្ត។ វឌ្ឍនភាពនៃការអនុវត្តទិសដៅការងារនីមួយៗ មានសង្ខេបជូនដូចខាងក្រោម៖

#### ២.១.១ ការរៀបចំឯកសារចេញនានា ដែលពាក់ព័ន្ធនឹង *ផ.យ.អ.ជ.*

បន្ទាប់ពីបញ្ចប់ការរៀបចំ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (ផ.យ.អ.ជ.) បច្ចុប្បន្នកម្ម ២០០៩-២០១៣* និងទទួលបានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា រដ្ឋសភា ព្រឹទ្ធសភា និង ឡាយព្រះហស្តលេខាដោយព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លើព្រះរាជក្រមដើម្បីដាក់ឲ្យប្រើប្រាស់ជាផ្លូវការ មកអគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ បានរៀបចំការផ្សព្វផ្សាយ *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម*

*២០០៩-២០១៣*នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងសង្គមស៊ីវិល និងអ្នកដែលមានចំណែកពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្តនៅទូទាំងប្រទេស។

ដើម្បីអនុវត្ត*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣* និងដើម្បីធ្វើជាធាតុចូលសម្រាប់រៀបចំច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ បានរៀបចំ *កម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) បីឆ្នាំរំកិល* ជារៀងរាល់ឆ្នាំ (២០១០-១២, ២០១១-១៣, ២០១២-១៤, ២០១៣-១៥, ២០១៤-១៦)។

ដូចបានកំណត់នៅក្នុង ជំពូកទី៦ នៃ *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣* ដែលតម្រូវឲ្យធ្វើការពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្ត*ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣*អគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ បានសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអ្នកដែលមានចំណែកពាក់ព័ន្ធទាំងអស់ រៀបចំ៖

- របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១១ នៃការអនុវត្ត *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣*។
- ពិនិត្យនិងកែសម្រួលសូចនាករតាមដានត្រួតពិនិត្យនិងវាយតម្លៃសំខាន់ៗ។
- រៀបចំរបាយការណ៍និងធ្វើបច្ចុប្បន្នភាព*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.)* (ឆ្នាំ២០១០, ២០១១, ២០១២, និង ២០១៣)។
- រៀបចំរបាយការណ៍និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពទីក្រុងអ៊ីស្តង់ប៊ុល (ស្តីពីប្រទេសដែលមានការអភិវឌ្ឍតិចតួច)។

ស្របពេលជាមួយគ្នានេះ ក្រសួងផែនការក៏បានពង្រឹងដំណើរការនិងវិធីសាស្ត្ររៀបចំផែនការនៅថ្នាក់ក្រោមជាតិ ក្នុងបរិការណ៍វិមជ្ឍការនិងវិសហមជ្ឈការ និងបានពង្រឹងសមត្ថភាពរបស់មន្ត្រីរបស់ក្រសួងផែនការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ២.១.២ ការរៀបចំធាតុចេញពិសេសផ្សេងទៀត ដែលនឹងត្រូវបង្កើតដោយអគ្គនាយកដ្ឋានផែនការ

### កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ៖

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្របានបង្កើតឡើងក្នុងឆ្នាំ២០០៦ ក្នុងគោលបំណងជួយជំរុញការកាត់បន្ថយភាពក្រីក្រឲ្យកាន់តែឆាប់រហ័ស តាមរយៈ ការផលិតទិន្នន័យគ្រួសារក្រីក្រ ដែលមានលក្ខណៈជាប្រព័ន្ធ និងជាសេរី ជូនដល់ស្ថាប័នរាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល សម្រាប់ ការតម្រង់ទិសក្នុងការផ្តល់ជំនួយ សេវាកម្ម ដល់អ្នកក្រីក្រពិតប្រាដក និងដើម្បីជួយពួកគាត់ឲ្យរួចផុតពីភាពក្រីក្រ ឬការពារពួកគាត់ កុំឲ្យធ្លាក់កាន់តែជ្រៅទៅក្នុងភាពក្រីក្រ។ ទិន្នន័យគ្រួសារក្រីក្រ ជាឧបករណ៍ដ៏សំខាន់សម្រាប់បម្រើដល់កម្មវិធីគាំពារសេវាសង្គម។

ហេតុមកដល់ឆ្នាំ២០១១ កម្មវិធីនេះ បានគ្របដណ្តប់លើតំបន់ជនបទនៅទូទាំងប្រទេស និងបន្តធ្វើបច្ចុប្បន្នភាពជារៀងរាល់បីឆ្នាំម្តង។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើនេះ កម្មវិធីបានកំណត់សកម្មភាពជាក់លាក់នៅក្នុងគោលដៅទី៣ នៃ *ផ.យ.ផ.ក. ២០០៩-២០១៣* និង *ផែនការប្រតិបត្តិប្រចាំឆ្នាំ* ។ វឌ្ឍនភាពនៃការសម្រេចបាន មានដូចខាងក្រោមៈ

- បានរៀបចំផែនការប្រតិបត្តិកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឆ្នាំ២០១២-២០១៤ និងផែនការសកម្មភាពប្រចាំឆ្នាំ ជារៀងរាល់ឆ្នាំនៃការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។
- បានធ្វើការកែសម្រួលនិងបោះពុម្ព សៀវភៅណែនាំ ស្តីពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ការតាមដានត្រួតពិនិត្យការអនុវត្តសញ្ញាណកម្មគ្រួសារក្រីក្រ ប្រព័ន្ធគណនេយ្យ ខិត្តប័ណ្ណព័ត៌មាន ទំរង់បែបបទនិងឯកសារផ្សេងៗ ។
- បានពង្រីកតំបន់គ្របដណ្តប់នៃការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅគ្រប់ភូមិដែលមានលក្ខណៈជនបទ ទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- បានផលិតឌីវីឌីនិងសៀវភៅ របាយការណ៍ចេញពីមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ និងផ្សព្វផ្សាយប្រើប្រាស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- អនុក្រឹត្យស្តីពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានរាជរដ្ឋាភិបាលនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១១ និងត្រូវបានផ្សព្វផ្សាយដល់គ្រប់ក្រសួងស្ថាប័ន រាជធានី ខេត្ត អង្គការជាតិ-អន្តរជាតិដែលពាក់ព័ន្ធ និងសង្គមស៊ីវិល ។
- បានរៀបចំរបាយការណ៍វឌ្ឍនភាព និងលទ្ធផលនៃការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ រៀងរាល់ឆ្នាំ ជូនរាជរដ្ឋាភិបាល ។
- បានរៀបចំកិច្ចប្រជុំប្រចាំខែ ដើម្បីពិនិត្យវឌ្ឍនភាពការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងលើកទិសដៅដើម្បីអនុវត្តបន្ត ។
- បានរៀបចំកម្មវិធីកុំព្យូទ័រដែលមានឈ្មោះថា "ប្រព័ន្ធព័ត៌មានអាត្លាសអត្តសញ្ញាណកម្មគ្រួសារក្រីក្រ - The Interactive IDPoor ATLAS" ។
- បានរៀបចំបង្កើតផ្នែកទន់មូលដ្ឋានទិន្នន័យផ្ទាល់តាមប្រព័ន្ធអ៊ិនធ័រណិត(Database Online Software)ដើម្បីផ្តល់ភាពងាយស្រួលដល់ការគ្រប់គ្រងទិន្នន័យគ្រួសារក្រីក្រ និងការចែកចាយទិន្នន័យនេះ ដល់អ្នកប្រើប្រាស់ឲ្យកាន់តែទូលំទូលាយ ។
- បានរៀបចំកិច្ចប្រជុំជាមួយមន្ត្រីមន្ទីរផែនការរាជធានី ខេត្ត នៃខេត្តគោលដៅដើម្បីផ្តល់ការណែនាំអំពីដំណើរការ អត្តសញ្ញាណកម្មគ្រួសារក្រីក្រ មុននឹងចាប់ផ្តើមអនុវត្ត ។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ខេត្ត ស្តីពីការចាប់ផ្តើមអនុវត្តអត្តសញ្ញាណកម្មគ្រួសាក្រីក្រ ។

- បានរៀបចំបណ្តុះបណ្តាលនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដល់មន្ត្រីមន្ទីរផែនការរាជធានី ខេត្ត ក្រុមសម្របសម្រួលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបណ្តុះបណ្តាលបន្តដល់ក្រុមតំណាងគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ និងក្រុមតំណាងភូមិ ។
- បានរៀបចំកិច្ចប្រជុំពាក់កណ្តាលជុំជាមួយមន្ត្រីមន្ទីរផែនការដើម្បីពិនិត្យវឌ្ឍនភាពការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងលើកទិសដៅដើម្បីអនុវត្តបន្ត ។
- បានចុះតាមដានត្រួតពិនិត្យការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅមូលដ្ឋាន ជាពិសេសនៅតាមឃុំ សង្កាត់ និងភូមិ ។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយទិន្នន័យគ្រួសារក្រីក្រ នៅថ្នាក់ជាតិ ថ្នាក់ខេត្តនិងក្រុងស្រុក។
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការថតរូបគ្រួសារក្រីក្រ
- បានបោះពុម្ពនិងផ្តល់ប័ណ្ណសមធម៌ចំនួនប្រមាណ ២៥០០០០សន្លឹក ក្នុង១ឆ្នាំផ្តល់ដល់គ្រួសារក្រីក្រ
- ចូលរួមរៀបចំគោលនយោបាយប្រព័ន្ធសុវត្ថិភាពសង្គម របស់រាជរដ្ឋាភិបាល សំដៅជានាំឲ្យការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ ជាប្រភពព័ត៌មានចំបងក្នុងការធ្វើអន្តរាគមន៍កាត់បន្ថយភាពក្រីក្រ ។
- បានរៀបចំនិងដំណើរការវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់មន្ត្រីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងក្រុមការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ រាជធានីនិងបណ្តាខេត្ត ក្នុងជុំទី៦ និងជុំទី៧ ។
- បាននិងកំពុងរៀបចំនីតិវិធីអត្តសញ្ញាណ កម្មគ្រួសារក្រីក្រនៅតំបន់ប្រជុំជន ។

### កម្មវិធីបញ្ចូលជាតិអ៊ីយ៉ូដក្នុងអំបិលជាសកលៈ

- បានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំរបស់អនុគណៈកម្មការជាតិលប់បំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូដ ។
- បានរៀបចំរបាយការណ៍ស្តីពី ការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភប្រចាំឆ្នាំ ជារៀងរាល់ឆ្នាំ ។
- បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងលទ្ធផលការងារអាហារូបត្ថម្ភ ។
- បរិមាណផលិតផលអំបិលអ៊ីយ៉ូដ ដែលផលិតបានជាមធ្យមប្រចាំឆ្នាំ ចំនួន ១១១៥២០តោន ស្មើនឹង១១១% នៃតម្រូវការប្រើប្រាស់ប្រចាំឆ្នាំ ។
- បានបន្តដំណើរការផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យស្តីពី ការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដសារៈសំខាន់នៃការប្រើប្រាស់អំបិលអ៊ីយ៉ូដ និងឥទ្ធិពលនៃបញ្ហាកង្វះជាតិអ៊ីយ៉ូដ ដល់អាជ្ញាធរដែនដីថ្នាក់ក្រោមជាតិ ដើម្បីផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋ តាមបណ្តាខេត្តមួយចំនួន ជាពិសេសខេត្តជាប់ព្រំប្រទល់ប្រទេសវៀតណាម និងថៃ។
- បានរៀបចំនិងបោះពុម្ពសៀវភៅអប់រំសុខភាពស្តីពី សារៈសំខាន់នៃការប្រើប្រាស់ចំណីអាហារសម្បូរជាតិអ៊ីយ៉ូដ ។

- បានចុះត្រួតពិនិត្យជាប្រចាំអំពីគុណភាពអំបិលអ៊ីយ៉ូដនៅទីកន្លែងផលិត ស្តុក ការចរាចរ និងទីកន្លែងលក់ដុំនិងលក់ រាយអំបិលអ៊ីយ៉ូដ ។
- បានរៀបចំកិច្ចប្រជុំប្រចាំខែ ដើម្បីពិនិត្យវឌ្ឍនភាពការអនុវត្តការងារ និងដោះស្រាយបញ្ហាប្រឈម ។
- បានរៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំបន្ទាប់។

## កម្មវិធីបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ៖

- បានរៀបចំសេចក្តីសម្រេចស្តីពីការបង្កើតអនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ។
- បានរៀបចំប្រកាសស្តីពី ការផលិតនិងការប្រើប្រាស់ទឹកត្រីនិងទឹកស៊ីអ៊ីវមានជាតិដែក និងបានផ្សព្វផ្សាយដល់ក្រសួងស្ថាប័នពាក់ព័ន្ធ និងផលិតករទឹកត្រីនិងទឹកស៊ីអ៊ីវ ។
- បានរៀបចំប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់បិតលើផលិតផលដែលមានបញ្ចូលជាតិដែក ។
- បានរៀបចំផែនការប្រតិបត្តិរយៈពេល៥ឆ្នាំ ២០១១-២០១៥ សម្រាប់អនុវត្តកម្មវិធីបញ្ចូលជាតិដែកក្នុងទឹកត្រី ទឹកស៊ីអ៊ីវ និងជីវជាតិអាក្នុងប្រេងឆា។
- បានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ របស់អនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ។
- បានរៀបចំវេទិកាអាហារូបត្ថម្ភស្តីពី អាហាសំបូរជាតិដែក ។
- បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា រវាងអនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ និងអង្គការ Rachaស្តីពីកម្មវិធីបញ្ចូលជាតិដែកក្នុងទឹកត្រីនិងទឹកស៊ីអ៊ីវ និងការបញ្ចូលជីវជាតិអាក្នុងប្រេងឆានៅកម្ពុជា ឆ្នាំ២០១១-២០១៥។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីកម្មវិធីបញ្ចូលជាតិដែកក្នុងទឹកត្រីនិងទឹកស៊ីអ៊ីវ និងការបញ្ចូលជីវជាតិអាក្នុងប្រេងឆានៅកម្ពុជា នៅគ្រប់បណ្តាខេត្តនិងរាជធានី ដោយបែងចែកជា៩មណ្ឌល ដែលមានការចូលរួមសមាជិក សមាជិកាគណៈកម្មាធិការសម្របសម្រួលការងារអាហារូបត្ថម្ភ អង្គការពាក់ព័ន្ធ និងសិប្បករផលិតទឹកត្រី ទឹកស៊ីអ៊ីវ សរុបចំនួន៣២៥នាក់។
- បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាងអនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ អង្គការ Rachaនិងសិប្បករផលិតទឹកត្រី ទឹកស៊ីអ៊ីវ ។
- រហូតដល់ខែវិច្ឆិកា ឆ្នាំ២០១៣ នេះ សិប្បកម្មផលិតទឹកត្រីចំនួន ៤១កន្លែង បានស្ម័គ្រចិត្តសហការជាមួយ អនុគណៈកម្មការជាតិបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ក្នុងការបញ្ចូលជាតិដែកក្នុងទឹកត្រីនិងទឹកស៊ីអ៊ីវ។ បរិមាណផលិតផលទឹកត្រីនិងទឹកស៊ីអ៊ីវមានជាតិដែក ផលិតបានចំនួន ៥១៤៩៥០៧លីត្រ។

- បានរៀបចំ បោះពុម្ពនិងផ្សព្វផ្សាយសៀវភៅអប់រំសុខភាពភាពស្តីពីសារៈសំខាន់នៃការប្រើប្រាស់ចំណីអាហារសំបូរជាតិដែក និងជីវជាតិអា និង សារអប់រំសុខភាព ស្តីពីសារៈសំខាន់នៃការប្រើប្រាស់ទឹកត្រីនិងទឹកស៊ីអ៊ីវមានជាតិដែក។

បានបន្តចូលរួម ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយដៃគូអភិវឌ្ឍន៍ ដូចខាងក្រោម៖

- ចូលរួមរៀបចំ អនុវត្ត និងវាយតម្លៃកម្មវិធីប្រចាំប្រទេស ២០១១-២០១៥នៃកិច្ចកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹង មូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) នៅក្រោមក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍សហប្រជាជាតិ
- ចូលរួមរៀបចំ អនុវត្ត និងវាយតម្លៃកម្មវិធីប្រចាំប្រទេស ២០១១-២០១៥នៃកិច្ចកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹង មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) នៅក្រោមក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍សហប្រជាជាតិ
- ចូលរួមរៀបចំ អនុវត្ត និងវាយតម្លៃកម្មវិធីប្រចាំប្រទេស ២០១១-២០១៥នៃកិច្ចកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹង ដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត នៅក្រោមក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍សហប្រជាជាតិ។

បានបន្តចូលរួម និងរួមចំណែកក្នុង យន្តការអន្តរក្រសួង ដូចខាងក្រោម៖

- យន្តការសេវាច្រកចេញចូលតែមួយ សម្រាប់វិនិយោគ
- យន្តការនៃគណៈកម្មាធិការ ក្រុមការងារ និងក្រុមប្រឹក្សានានា

បានពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-វៀតណាម លើផ្នែកការកសាងសមត្ថភាពដល់មន្ត្រីផែនការ ថ្នាក់ជាតិនិង ថ្នាក់ក្រោមជាតិ តាមរយៈការបណ្តុះបណ្តាល រយៈពេលខ្លី និង វែង និង តាមរយៈទស្សនកិច្ចសិក្សារួមមាន៖

- គណៈប្រតិភូក្រសួងផែនការកម្ពុជាបានទៅធ្វើទស្សនកិច្ចសិក្សានៅសាធារណរដ្ឋសង្គមនិយមវៀតណាមចំនួន៨លើក មានមន្ត្រីផែនការពីក្រសួង និងពីបណ្តារាជធានីខេត្តចូលរួមចំនួន១២០នាក់។
- គណៈប្រតិភូក្រសួងផែនការនិងវិនិយោគវៀតណាមបានមកធ្វើទស្សនកិច្ចសិកស្សានៅព្រះរាជាណាចក្រកម្ពុជាចំនួន៤លើក មានមន្ត្រីសរុបចំនួន៦០នាក់។
- ក្រសួងផែនការ និងវិនិយោគវៀតណាមបានបញ្ជូនបានបញ្ជូនមន្ត្រីជំនាញ*ផ.ស.ស.*មកកម្ពុជាចំនួន០២លើក ដើម្បីសហកាជាមួយក្រុមមន្ត្រីជំនាញរបស់ក្រសួងផែនការកម្ពុជា រៀបចំវគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹង ពីវិធីសាស្ត្រគណនា *ផ.ស.ស.*នៅខេត្តកំពង់ចាម និង ខេត្តកោះកុង ជូនដល់មន្ត្រីមន្ទីរផែនការរាជធានីខេត្តទាំង២៤។
- ក្រសួងផែនការ និងវិនិយោគវៀតណាម បានបញ្ជូនមន្ត្រីជំនាញ*ផ.ស.ស.*មកកម្ពុជា ដើម្បីសហការជាមួយក្រុមមន្ត្រីជំនាញក្រសួងផែនការកម្ពុជា ធ្វើបណ្តុះបណ្តាលដល់មន្ត្រីមន្ទីរផែនការរាជធានី

ខេត្ត អំពីការរៀបចំប្រមូលចងក្រងព័ត៌មានសម្រាប់គណនា*ផ.ស.ស.*និងការអនុវត្តជាក់ស្តែងធ្វើការផលិតសាកល្បង*ផ.ស.ស.*សម្រាប់ខេត្តកំពង់ឆ្នាំង និង ខេត្តព្រះសីហនុ។

- ក្រសួងផែនការ និងវិនិយោគវៀតណាម បានបញ្ជូនមន្ត្រីជំនាញគេហទំព័រមកកម្ពុជាចំនួន ០២ លើក ដើម្បីមកជួយបំពាក់សម្ភារៈបរិក្ខារ និងបណ្តុះបណ្តាលដល់មន្ត្រីក្រសួងផែនការ អំពីចំណេះដឹងបច្ចេកទេសសម្រាប់គ្រប់គ្រង និងដំណើរការគេហទំព័រតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា ឡាវ វៀតណាម នៅក្រសួងផែនការ។

បានពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-វៀតណាម លើការងារផ្លាស់ប្តូរគណៈប្រតិភូរវាងស្ថាប័នផែនការប្រទេសទាំងពីរ៖

- ក្រសួងផែនការកម្ពុជា និងក្រសួងផែនការនិងវិនិយោគវៀតណាម បានរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងផែនការកម្ពុជា និងក្រសួងផែនការនិងវិនិយោគវៀតណាម ដោយធ្វើឆ្លាស់គ្នា នៅកម្ពុជា និង នៅវៀតណាមបានចំនួន០៥ លើក ។
- ក្រសួងផែនការកម្ពុជា និងក្រសួងផែនការនិងវិនិយោគវៀតណាម បានរៀបចំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ថ្នាក់រដ្ឋលេខាធិការ/អនុរដ្ឋមន្ត្រីស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងផែនការកម្ពុជា និងក្រសួងផែនការនិងវិនិយោគវៀតណាម ដោយធ្វើឆ្លាស់គ្នា នៅកម្ពុជា និង នៅវៀតណាមបានចំនួន០៤ លើក។

បានពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-វៀតណាម លើសកម្មភាពការងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា ឡាវ និង វៀតណាម

- សហការរៀបចំឯកសារជាមួយក្រសួងពាក់ព័ន្ធនិងចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះនៃកិច្ចអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងកិច្ចប្រជុំពាក់ព័ន្ធចំនួន០៤លើក។
- បានចូលរួមកិច្ចប្រជុំក្រុមការងារ(WGM)នៃតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា ឡាវ វៀតណាម (-CLV DTA) ដើម្បីពិភាក្សាបញ្ចប់របាយការណ៍ នៃការវាយតម្លៃការអនុវត្តផែនការមេដល់ឆ្នាំ២០២០ និងកែសម្រួលការបកប្រែជាភាសាខ្មែរនិងឡាវនៃផែនការមេ។
- បាននិងកំពុងដំណើរការរៀបចំគេហទំព័រសម្រាប់កម្ពុជា ក្រោមកិច្ចសហប្រតិបត្តិការ កម្ពុជា ឡាវ វៀតណាម។

បានពង្រឹងកិច្ចសហប្រតិបត្តិការ លើការចូលរួមក្នុងសកម្មភាពការងារកិច្ចសហប្រតិបត្តិការអាស៊ាន ដោយបាន៖

- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការដឹកនាំនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន (Steering Committee AMBDC) បានចំនួន០៤លើក ។

- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការដឹកនាំនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន (AMBDC) ថ្នាក់រដ្ឋមន្ត្រី និងចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ ចំនួន ០៤លើក ។
- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាម
- ចូលរួមកិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ពាណិជ្ជកម្មតាមព្រំដែនកម្ពុជាវៀត-ណាម ចំនួន ០៣លើក។
- ចូលរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំឯកសារសំខាន់ៗសម្រាប់ថ្នាក់ដឹកនាំចូលរួមកិច្ចប្រជុំប្រចាំឆ្នាំក្នុងអង្គការពាណិជ្ជកម្មពិភពលោក ។

## ២.២ សមិទ្ធផលសំខាន់ៗ ដែលវិទ្យាស្ថានជាតិស្ថិតិសម្រេចបាន

ឆ្លើយតបនឹងផែនការសកម្មភាពនិងទិសដៅដែលបានកំណត់ក្នុងផែនការមេស្ថិតិឆ្នាំ២០០៨-២០១៥ក៏ដូចជាផែនការយុទ្ធសាស្ត្រក្រសួងផែនការ *(ផ.យ.ផ.ក.) បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣* វិទ្យាស្ថានជាតិស្ថិតិបានអនុវត្តនិងសម្រេចបាននូវសមិទ្ធផលសំខាន់ៗដូចខាងក្រោមៈ

### ២.២.១ សម្របសម្រួលនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធស្ថិតិជាតិនិងសមត្ថភាពស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ

- អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តក្នុងខែកក្កដាឆ្នាំ ២០១០។
- ការសម្របសម្រួល និងកិច្ចសហការនៅក្នុងប្រព័ន្ធស្ថិតិជាតិតាមរយៈដំណើរនៃកិច្ចប្រជុំជាប្រចាំរបស់ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវបានអនុវត្ត។ជាក់ស្តែងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្ថិតិបានធ្វើឡើងចំនួន៣លើកនិងកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិបានធ្វើឡើងចំនួន១៥លើក។
- បានរៀបចំអនុក្រឹត្យស្តីពីកាលបរិច្ឆេទនៃការធ្វើជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១។
- បានរៀបចំអនុក្រឹត្យស្តីពីកាលបរិច្ឆេទនៃការធ្វើជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣។
- ធ្វើការពិនិត្យឡើងវិញកែសម្រួលច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ដើម្បីឆ្លើយតបតម្រូវការគាំទ្រហិរញ្ញវត្ថុសម្រាប់ប្រព័ន្ធស្ថិតិជាតិ និងសារៈសំខាន់របស់ទិន្នន័យស្ថិតិក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ*ផ.យ.អ.ជ.*។តាមរយៈនេះវិទ្យាស្ថានជាតិស្ថិតិដោយមានការគាំទ្រពីអង្គការ OECD/PARIS21 និងអង្គការ Sida/SCB បានដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយបណ្តាក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍដែលពាក់ព័ន្ធ និងកិច្ចប្រជុំគណៈកម្មាធិការសម្រប

សម្រួលស្ថិតិជាច្រើនលើកព្រមទាំងបានរៀបចំសិក្ខាសាលាកម្រិតខ្ពស់ថ្នាក់ជាតិស្តីពីការគាំទ្រស្ថិតិនៅខែតុលាឆ្នាំ២០១៣។

- ធ្វើឱ្យប្រសើរឡើងនូវសមាហរណកម្មនៃប្រព័ន្ធស្ថិតិជាតិទៅក្នុងតំបន់និងសកលលោក ក៏ដូចជាការពង្រឹងសមត្ថភាពរបស់វិទ្យាស្ថានជាតិស្ថិតិតាមរយៈការចូលរួមកិច្ចប្រជុំ សិក្ខាសាលាទស្សនកិច្ចសិក្សានិងវគ្គបណ្តុះបណ្តាលផ្សេងៗ ដែលចំនួនមន្ត្រីវិទ្យាស្ថានជាតិស្ថិតិបានចូលរួមមានការកើនឡើងពី៩៩នាក់ រហូតដល់១១៥នាក់ ក្នុងអំឡុងពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣។ ក្រៅពីនេះ តាមរយៈការបណ្តុះបណ្តាលជំនាញរយៈពេលខ្លី មធ្យម និងវែង មានចំនួន២០៣នាក់។ ក្នុងនោះការបណ្តុះបណ្តាលនៅក្នុងប្រទេសមានចំនួន១៥០នាក់ និងនៅក្រៅប្រទេសមានចំនួន៥៣នាក់ (វគ្គបណ្តុះបណ្តាលស្ថិតិបឋម និងស្ថិតិកម្រិតខ្ពស់នៅប្រទេសវៀតណាមចំនួន២១នាក់ វគ្គបណ្តុះបណ្តាលជំនាញជ្រើសរើសសំណាកគំរូ និងថ្នាក់អនុបណ្ឌិតនៅប្រទេសឥណ្ឌាចំនួន៥នាក់ វគ្គបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មានវិទ្យានៅប្រទេសជប៉ុនចំនួន ៩នាក់ និងវគ្គបណ្តុះបណ្តាលវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នៅសាធារណៈរដ្ឋកូរ៉េចំនួន ១៨នាក់)។ ដោយឡែកក្នុងអំឡុងពេលដូចគ្នានេះ មន្ត្រីវិទ្យាស្ថានជាតិស្ថិតិទាំងនៅការិយាល័យកណ្តាលនិងរាជធានី ខេត្តចំនួន៦៦៤នាក់បានទទួលការបណ្តុះបណ្តាលនៅក្នុងប្រទេសតាមរយៈគម្រោងគាំទ្ររបស់អង្គការ JICA និង Sida។
- ទទួលប្រតិភូស្ថិតិពីបណ្តាប្រទេសនានា ដែលបានមកធ្វើទស្សនកិច្ចសិក្សានៅវិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការជាច្រើនលើកដូចជាប្រតិភូស្ថិតិមកពីប្រទេសឡាវវៀតណាម យូហ្គាន់ដា បង់ក្លាដេស សាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងសាធារណៈរដ្ឋកូរ៉េ ។
- ចំនួនមន្ត្រីវិទ្យាស្ថានជាតិស្ថិតិបានកើនឡើងពី៣១០នាក់រហូតដល់៣៤៥នាក់ក្នុងអំឡុងពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៣។
- ថវិការបស់រាជរដ្ឋាភិបាលសម្រាប់វិទ្យាស្ថានជាតិស្ថិតិបានកើនឡើងពី១,១៣៤លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៩រហូតដល់២,៤៧០លានដុល្លារអាមេរិកនៅឆ្នាំ២០១៣។

### ២.២.២ ប្រព័ន្ធស្ថិតិជាតដែលទាន់ពេលវេលាមានទំនាក់ទំនងគ្នានិងមានការឆ្លើយតប

- បានអនុវត្តអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាទ្រង់ទ្រាយធំឆ្នាំ២០០៩ និងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាប្រចាំឆ្នាំ២០១០ ឆ្នាំ២០១១ ឆ្នាំ២០១២ និងឆ្នាំ២០១៣
- បានអនុវត្តការចុះស្រង់បញ្ជីសហគ្រាសឆ្នាំ២០០៩
- បានអនុវត្តអង្កេតសាកល្បងសហគ្រាសឆ្នាំ២០១០
- បានអនុវត្តអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០១០
- បានអនុវត្តជំរឿនសហគ្រាសឆ្នាំ២០១១
- បានអនុវត្តអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកម្ពុជាឆ្នាំ២០១២
- បានអនុវត្តអង្កេតសាកល្បងស្តីពីពលកម្មកុមារក្នុងវិស័យនេសាទ និងវារីវប្បកម្មឆ្នាំ២០១២

- បានអនុវត្តអង្កេតពីសាលាទៅការងារឆ្នាំ២០១២
- បានអនុវត្តអង្កេតអំពើហិង្សាលើកុមារ និងមនុស្សវ័យក្មេងឆ្នាំ២០១២
- បានអនុវត្តអង្កេតចន្លោះជំរឿនប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣
- បានអនុវត្តជំរឿនកសិកម្មឆ្នាំ ២០១៣
- បានបញ្ចប់ការជួសជុលបន្ទប់កុំព្យូទ័រ និងបំពាក់សំភារៈបរិក្ខារចំនួន ២០ រាជធានីខេត្ត

## ២.២.៣ ធ្វើឱ្យប្រសើរឡើងការផ្សព្វផ្សាយនិងបង្កើនការប្រើប្រាស់ស្ថិតិផ្លូវការ

- បានធ្វើបច្ចុប្បន្នកម្មកាំអ៊ិនហ្វូ (CAMInfo) ប្រចាំឆ្នាំបាន១២ជំនាន់ ចាប់ពីឆ្នាំ២០០៤ ដល់ ឆ្នាំ ២០១៣ ដែលគាំទ្រដោយអង្គការ UNICEF
- បានផលិត CensusInfo ជំនាន់ទីមួយដែលគាំទ្រដោយ UNFPA
- បានរៀបចំ និងប្រកាសផ្សព្វផ្សាយ របាយការណ៍ប៉ាន់ស្មានអំពីភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភ នៅតំបន់តូចៗ (ថ្នាក់ខេត្ត ស្រុក ឃុំ)។
- បានចងក្រងនិងផ្សព្វផ្សាយ ម៉េតាដាតា និងមីក្រូទិន្នន័យ នៃអង្កេត និងជំរឿន ក្នុងវេសាយណាដា តាមរយៈវេបសាយ របស់វិទ្យាស្ថានជាតិស្ថិតិ ។
- បានផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការនិងបណ្តុះបណ្តាលការប្រើប្រាស់កាំអ៊ីនហ្វូដល់មន្ត្រីតាម តំបន់ (២៤ រាជធានី-ខេត្ត) និងមន្ត្រីតាមបណ្តាក្រសួងស្ថាប័ននានាអង្គការជាតិ និងអន្តរជាតិ ផ្នែកឯកជនគ្រឹះស្ថានអប់រំ និងសិក្សាស្រាវជាវប្រមាណ ១០០០នាក់
- បានចងក្រងនិងបោះពុម្ពផ្សាយព្រឹត្តិបត្រសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែ ប្រចាំត្រីមាស និង ប្រចាំឆ្នាំ។
- បានចងក្រង និងបោះពុម្ពផ្សាយព្រឹត្តិបត្រគណនេយ្យជាតិប្រចាំឆ្នាំ
- បានចងក្រង និងបោះពុម្ពផ្សាយសៀវភៅស្ថិតិទំនិញពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជាប្រចាំឆ្នាំ
- បានចងក្រង និងបោះពុម្ពផ្សាយសៀវភៅកម្រងស្ថិតិប្រចាំឆ្នាំ
- បានចងក្រង និងបោះពុម្ពផ្សាយកូនសៀវភៅស្ថិតិយេនឌ័រប្រចាំឆ្នាំ
- បានចងក្រង និងបោះពុម្ពផ្សាយសៀវភៅចំណាត់ថ្នាក់វិស័យសេដ្ឋកិច្ចកម្ពុជា
- បានរៀបចំរបាយការណ៍ស្ថិតិកសិកម្មដោយផ្អែកលើលទ្ធផលអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា
- បានរៀបចំនិងផ្សព្វផ្សាយរបាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០០៩ និងឆ្នាំ២០១០ និងផ្សព្វផ្សាយតាមគេហទំព័រវិទ្យាស្ថានជាតិស្ថិតិនូវតារាងស្ថិតិសង្ខេប ឆ្នាំ២០០៤ ឆ្នាំ២០០៧ ឆ្នាំ ២០០៨ ឆ្នាំ២០០៩ ឆ្នាំ២០១០ ឆ្នាំ២០១១ និងឆ្នាំ២០១២
- បានរៀបចំនិងផ្សព្វផ្សាយរបាយការណ៍លទ្ធផលចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ ២០០៨
- បានរៀបចំនិងផ្សព្វផ្សាយរបាយការណ៍វិភាគស៊ីជម្រៅតាមប្រធានបទចំនួន១៤ ផ្អែកតាមលទ្ធ ផលជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨

- បានរៀបចំនិងផ្សព្វផ្សាយរបាយការណ៍វិភាគតាមរាជធានី ខេត្តទាំង២៤ ផ្អែកតាមលទ្ធផលជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨
- បានរៀបចំនិងផ្សព្វផ្សាយរបាយការណ៍អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០១០
- បានរៀបចំទិវាស្ថិតិពិភពលោកឆ្នាំ២០១០
- បានរៀបចំចំណាត់ថ្នាក់ទីប្រជុំជនឡើងវិញ ឆ្នាំ២០១១ ផ្អែកតាមលទ្ធផលជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨
- បានរៀបចំ និងផ្សព្វផ្សាយរបាយការណ៍អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកម្ពុជាឆ្នាំ២០១២
- បានរៀបចំ និងផ្សព្វផ្សាយរបាយការណ៍អង្កេតចន្លោះជំរឿនប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣
- បានរៀបចំ និងផ្សព្វផ្សាយលទ្ធផលវិភាគស៊ីជម្រៅតាមប្រធានបទចំនួន៤ ផ្អែកតាមលទ្ធផលអង្កេតចន្លោះជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣
- បានរៀបចំ និងផ្សព្វផ្សាយរបាយការណ៍ស្តីពីមនុស្សចាស់នៅកម្ពុជាឆ្នាំ២០១២
- បានរៀបចំ និងផ្សព្វផ្សាយរបាយការណ៍ស្តីពីស្ត្រី និងចំណាកស្រុកឆ្នាំ២០១៣
- បានរៀបចំ និងប្រកាសផ្សព្វផ្សាយរបាយការណ៍ស្តីពីការចុះស្រង់បញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជាឆ្នាំ២០០៩ អង្កេតសហគ្រាសសាកល្បងឆ្នាំ២០១០ របាយការណ៍វិភាគលម្អិតតាមប្រធានបទចំនួន១១ និងប្រកាសផ្សព្វផ្សាយលទ្ធផលចុងក្រោយជំរឿនសហគ្រាសឆ្នាំ២០១១។
- បានរៀបចំ និងបោះពុម្ពផ្សាយរបាយការណ៍ពាក់កណ្តាលអាណត្តិផែនការមេស្ថិតិឆ្នាំ២០១២
- បានរៀបចំ និងបោះពុម្ពផែនការមេជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២០១៤-២០២០
- បានរៀបចំ និងបោះពុម្ពផ្សាយរបាយការណ៍ប្រព័ន្ធស្ថិតិជាតិប្រចាំឆ្នាំចាប់តាំងពីឆ្នាំ២០១០
- ពង្រីកនិងកែលម្អគេហទំព័រវិទ្យាស្ថានជាតិស្ថិតិដោយបានដាក់បង្ហោះទិន្នន័យថ្មីៗ ដូចជា ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាប្រចាំឆ្នាំ ជំរឿនប្រជារាស្ត្រឆ្នាំ២០០៨ បញ្ជីសហគ្រាសកម្ពុជាឆ្នាំ២០០៩ សូចនាករសេទ្ធស្សន៍ថ្លៃទំនិញប្រើប្រាស់គណនេយ្យជាតិ របាយការណ៍ស្ថិតិនិងកម្រងឯកសារដែលទាក់ទងនឹងច្បាប់ស្ថិតិនិងអនុក្រឹត្យពាក់ព័ន្ធផ្សេងៗទៀតជាច្រើន។
- ផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវទិន្នន័យស្ថិតិ តាមរយៈមជ្ឈមណ្ឌលសេវាកម្មព័ត៌មានស្ថិតិ រួមមានរបាយការណ៍ទាក់ទឹងនឹងការធ្វើជំរឿននិងការអង្កេតនានា កម្រងទិន្នន័យស្ថិតិពីប្រព័ន្ធទិន្នន័យរដ្ឋបាលនិងឯកសារបោះពុម្ពផ្សាយផ្សេងៗដូចជាស៊ីឌីរ៉ូមព្រឹត្តប័ត្រស្ថិតិប្រចាំខែ ប្រចាំត្រីមាសប្រចាំឆមាសនិងប្រចាំឆ្នាំទៅដល់អ្នកប្រើប្រាស់ទិន្នន័យស្ថិតិទាំងអស់ នៅផ្ទៃក្នុងប្រទេសនិងក្របខ័ណ្ឌអន្តរជាតិ។

## ២.៣ សមិទ្ធផលសំខាន់ៗ ដែលអគ្គនាយកដ្ឋានផែនការ និងវិទ្យាស្ថានជាតិស្ថិតិ រួមគ្នាសម្រេចបាន

បានបន្តអនុវត្ត *ផែនការយុទ្ធសាស្ត្របញ្ញោបយេនឪ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដោយបាន៖

- រៀបចំគម្រោងពង្រឹងសមត្ថភាពដល់មន្ត្រីផែនការនិងស្ថិតិ នៅក្រសួងផែនការ និងមន្ទីរផែនការរាជធានី ខេត្ត។

- ពង្រឹងសមត្ថភាពស្តីពីការបញ្ជ្រាបយេនឌ័រតាមរយៈការបណ្តុះបណ្តាល ដល់សមាជិកក្រុមការងារយេនឌ័រក្រសួងផែនការ និងមន្ត្រីបង្គោលយេនឌ័រនៅមន្ទីរផែនការរាជធានី ខេត្ត។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការនិងស្ថិតិ ដល់ មន្ត្រីនិងថ្នាក់ដឹកនាំនៅក្រសួងផែនការនិងនៅថ្នាក់រាជធានី ខេត្ត និង ដល់និស្សិតមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការនិងស្ថិតិ។
- បន្តចូលរួមក្នុងសកម្មភាពយេនឌ័រ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការជាតិទន្លេមេគង្គ។
- បន្តចូលរួមរៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញា ស៊ី-ដ នៅកម្ពុជា ក្នុងក្របខ័ណ្ឌជាសមាជិកបច្ចេកទេសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីផ្ញើទៅអង្គការសហប្រជាជាតិ។
- វាយតម្លៃពីលទ្ធផលនៃការអនុវត្ត *ផែនការយុទ្ធសាស្ត្រសកម្មភាពបញ្ជ្រាបយេនឌ័រក្រសួងផែនការបច្ចុប្បន្នកម្ម (ផ.យ.ប.យ.ផ.ក) ២០០៩-២០១៣* ដើម្បីរៀបចំ *ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្រសួងផែនការ ២០១៤-២០១៨*។
- បានរៀបចំចងក្រងនិងប្រើប្រាស់ស្ថិតិយេនឌ័រ បំបែកតាមភេទ។

បានរៀបចំ អនុវត្ត និងវាយតម្លៃការអនុវត្ត*ផ.យ.ផ.ក បច្ចុប្បន្នកម្ម ២០០៩-២០១៣*តាមរយៈ*ផែនការប្រតិបត្តិប្រចាំឆ្នាំ (ឆ្នាំ២០១០, ២០១១, ២០១២, និង ២០១៣)*ដោយរួមមានសកម្មភាពដូចខាងក្រោម៖

- កិច្ចប្រជុំរួមគ្នារវាងអគ្គនាយកដ្ឋានផែនការនិងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីវាយតម្លៃការអនុវត្ត*ផែនការប្រតិបត្តិប្រចាំឆ្នាំមុន* មុននឹងឈានទៅរៀបចំ *ផែនការប្រតិបត្តិប្រចាំឆ្នាំថ្មី*។
- កិច្ចប្រជុំរួមគ្នារវាង អគ្គនាយកដ្ឋានផែនការ វិទ្យាស្ថានជាតិស្ថិតិ និង ដៃគូអភិវឌ្ឍន៍សំខាន់ៗ ដើម្បីពិនិត្យមើលលទ្ធភាពនៃការគាំទ្រ ទាំងថវិកា និងបច្ចេកទេស ដល់សកម្មភាពការងារជាអាទិភាព ដែលមានចែងក្នុង *ផែនការប្រតិបត្តិប្រចាំឆ្នាំ*។
- ដៃគូអភិវឌ្ឍសំខាន់ៗ បានបញ្ចូលផែនការសកម្មភាពប្រចាំឆ្នាំ(AWP)របស់ខ្លួន ទៅនឹងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងផែនការ។
- ដៃគូអភិវឌ្ឍសំខាន់ៗ បានផ្តល់ការគាំទ្រ ទាំងថវិកានិងបច្ចេកទេស សម្រាប់អនុវត្ត *ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងផែនការ*។
- បណ្តុះបណ្តាលចំណេះដឹងស្តីពីស្ថិតិមូលដ្ឋាន សម្រាប់ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ។
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយពី៖
  - វិធីសាស្ត្រនិងលទ្ធផលនៃការកំណត់ខ្សែបន្ទាត់ភាពក្រីក្រថ្មី
  - ឯកសារស្តីពីការបញ្ចូលទស្សនទានប្រជាសាស្ត្រទៅក្នុងការអភិវឌ្ឍ
  - លទ្ធផលនៃការវិភាគ ៤ប្រធានបទ ផ្អែកលើលទ្ធផលនៃការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០១០(១. កម្រិតនិងនិន្នាការប្រែប្រួលនៃការពន្យារកំណើត និងតម្រូវការផែនការគ្រួសារដែលមិនត្រូវបានឆ្លើយតបនៅកម្ពុជា ២. ការផ្តល់កំណើតរបស់យុវវ័យនិងលក្ខណៈប្រជា

សាស្ត្រសង្គមនិងកត្តាប្រឈម ៣. ការថែទាំសុខភាពមាតាក្រោយសម្រាលនិងកត្តាកំណត់ នៅកម្ពុជា និង ៤. កត្តាទាក់ទងនឹងការប្រើប្រាស់សេវាសុខភាពសម្រាប់កុមារដែលមានជំងឺរាគ និងគ្រុនក្ដៅ នៅកម្ពុជា)។

បានចូលរួមចំណែកទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ តាមរយៈ៖

- កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍ។
- ចូលរួមសិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលនានា។

ក្រុមការងារ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងផែនការ បានចូលរួមសកម្មភាពនានា សម្រាប់អនុវត្តផែនការកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំថវិកាជាតិ។

បានចូលរួមចំណែកជំរុញនិងអនុវត្ត ការប្រើប្រាស់នូវអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី នៅក្នុងការអនុវត្តការងារអាទិភាពទាំងឡាយរបស់ក្រសួងផែនការ។

បានចូលរួមចំណែកអនុវត្តផែនការសកម្មភាពអាទិភាពលើកទី៣ តាមរយៈ៖

- ការលើកកម្ពស់ផ្ដល់សេវាកម្មប្រកបដោយប្រសិទ្ធភាព របស់ក្រសួងផែនការ។
- ចូលរួមអនុវត្តយន្តការ និងពង្រឹងសមត្ថភាពសម្រាប់ការគ្រប់គ្រងការងារផ្ដល់ប្រាក់ចំណាយប្រតិបត្តិអាទិភាព (POC) ដោយផ្អែកលើលទ្ធផលការងារ សម្រាប់អនុវត្តការងាររបស់កម្មវិធី។

# ផ្នែកទី៣

# ផែនការយុទ្ធសាស្ត្រក្រសួងផែនការ ( ផ.យ.ផ.ក ) ២០១៤-២០១៨

## I. ប្រវត្តិដើម

*ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផ.យ.ផ.ក.) បច្ចុប្បន្នកម្ម ២០០៩-២០១៣* នឹងត្រូវបានបញ្ចប់អាណត្តិកាល នាចុងឆ្នាំ២០១៣ នេះ។ ដើម្បីបន្តរួមចំណែកអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់នៅក្នុង*ផ.យ.អ.ជ* និងដើម្បីធ្វើជាឧបករណ៍ សម្រាប់តម្រង់ទិសការគាំទ្រទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ របស់ដៃគូអភិវឌ្ឍន៍ដល់ក្រសួងផែនការ*ផ.យ.ផ.ក. ២០១៤-២០១៨* ត្រូវបានចាប់ផ្តើមរៀបចំឡើង។ *ផ.យ.ផ.ក. ២០១៤-២០១៨*គឺជាផែនការលើកទី៣របស់ក្រសួងផែនការដែលលើកទី១ គឺ*ផ.យ.ផ.ក.* ដែលមានអាណត្តិកាលពីឆ្នាំ២០០៦ដល់ឆ្នាំ២០១០និងទី២ គឺ *ផ.យ.ផ.ក. បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដែលត្រូវបានធ្វើបច្ចុប្បន្នភាពពី *ផ.យ.ផ.ក. ២០០៦-២០១០* កាលពីឆ្នាំ ២០០៩ ដើម្បីបន្ស៊ីអាណត្តិកាល ឲ្យត្រូវគ្នានឹងអាណត្តិកាល របស់ *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣*និង អាណត្តិកាលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដូចផែនការលើកទី១ និងទី២ ដែរ*ផ.យ.ផ.ក. ២០១៤-២០១៨*ជាយត្រូវបានរៀបចំឡើងដោយមន្ត្រីរបស់អគ្គនាយកដ្ឋានផែនការផ្ទាល់ ដោយមានកិច្ចសហការផ្ទៃក្នុងជាមួយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ នាយកដ្ឋានក្រោមឱវាទរបស់អគ្គនាយកដ្ឋានផែនការ និងវិទ្យាស្ថានជាតិស្ថិតិ និងដោយមានការគាំទ្រហិរញ្ញវត្ថុពី មូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) និង មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA)។

នៅក្នុងផ្នែកនេះ*(ផ.យ.ផ.ក. ២០១៤-២០១៨)*នឹងបង្ហាញពីទិសដៅការងារសំខាន់ៗ សម្រាប់អនុវត្តនៅក្នុងអំឡុងពេលនៃផែនការ ពីឆ្នាំ២០១៤-២០១៨ (នៅក្នុងចំណុចII)ជាមួយគ្នានឹងសកម្មភាពលម្អិតក្នុងទិសដៅការងារនីមួយៗ (ក្នុងតារាងម៉ាទ្រីស *ផ.យ.អ.ជ. ២០១៤-២០១៨*) ទាំងផ្នែកអគ្គនាយកដ្ឋានផែនការ វិទ្យាស្ថានជាតិស្ថិតិ និងផ្នែកការងាររួម។

## II. ទិសដៅការងារសំខាន់ៗ នៃ *ផ.យ.ផ.ក. ២០១៤-២០១៨*

### ២.១ សម្រាប់អគ្គនាយកដ្ឋានផែនការ

នៅក្នុងផែនការនេះ អគ្គនាយកដ្ឋានផែនការបានលើកទិសដៅការងារចំនួន៤ ដើម្បីអនុវត្តពីឆ្នាំ ២០១៤ ដល់ឆ្នាំ២០១៨។ នៅក្នុងទិសដៅការងារនីមួយៗ មានសកម្មភាពការងារជាច្រើន ដែលត្រូវអនុវត្ត នៅក្នុងអំឡុងពេលនៃផែនការនេះ។

## ទិសដៅការងារទី១៖ ការរៀបចំធាតុចេញនានា ដែលពាក់ព័ន្ធនឹង *ផយអជ*

១. រៀបចំ បោះពុម្ព និងផ្សព្វផ្សាយ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.)*។

២. រៀបចំ និងបោះពុម្ពផ្សាយ *កម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.)* ៣ឆ្នាំរំកិល។

៣. ពង្រឹងយន្តការកាងារផែនការ តាមរយៈ៖

- ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត *ផ.យ.អ.ជ.* តាមរយៈរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ និងរបាយការណ៍ពាក់កណ្តាលអាណត្តិ។
- រៀបចំរបាយការណ៍វឌ្ឍនភាព នៃការសម្រេចបាន *គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.)* ឆ្នាំ២០១៤ និង ២០១៥។
- រៀបចំរបាយការណ៍និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពទីក្រុងអ៊ីស្តង់ប៊ុល (ប្រទេសដែលមានការអភិវឌ្ឍតិចតួច)។
- គណនាអត្រាភាពក្រីក្រនៅកម្ពុជា ដោយប្រើប្រាស់ទិន្នន័យ អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ថ្មីៗ។
- រៀបចំរបាយការណ៍ស្តីពីភាពក្រីក្ររបស់កុមារ (ត្រូវការជំនាញការបរទេស)
- រៀបចំ និងតាមដានត្រួតពិនិត្យការអនុវត្តគោលនយោបាយជាតិប្រជាជន។

៤. រៀបចំប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង អភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ
- ការរៀបចំប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- អភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីការកសាងផែនការ

## ទិសដៅការងារទី២៖ ការរៀបចំធាតុចេញពិសេសផ្សេងទៀតដែលនឹងត្រូវបង្កើតឡើងដោយអគ្គនាយកដ្ឋានផែនការ

១. បន្តដំណើរការកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅទូទាំងប្រទេស

២. គាំទ្រការផ្តួចផ្តើមគំនិត/កម្មវិធីនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ តាមរយៈការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ដែលរួមមាន៖
- រៀបចំផែនការយុទ្ធសាស្ត្រលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភកម្ពុជា ២០១៤-២០១៨
- កម្មវិធីបញ្ចូលជាតិអ៊ីយ៉ូដក្នុងអំបិលជាសកល
- កម្មវិធីបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ

## ទិសដៅការងារទី៣៖ ការបន្តចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើឲ្យប្រសើរឡើង នូវប្រសិទ្ធភាពនៃធនធានអភិវឌ្ឍន៍ ដែលអាចមាន តាមរយៈ

១. ចូលរួមរៀបចំធាតុចូលរបស់ក្រសួងផែនការ សម្រាប់ការអនុវត្តយុទ្ធសាស្ត្រអនុវិស័យ ដោយធ្វើការជាមួយគ្រប់នាយកដ្ឋានក្នុងក្រសួងផែនការ ( ផែនការយុទ្ធសាស្ត្របញ្ជាបយេនឌ័រក្រសួងផែនការ)

២. អនុវត្តការងារដែលត្រូវបានកំណត់ដោយក្រុមការងារសម្រាប់គ្រប់គ្រងដំណើរការសុខដុមនីយកម្មការងារផែនការ ចំណាយវិនិយោគសាធារណៈ និងហិរញ្ញប្បទានសហប្រតិបត្តិការ (សម្រាប់ការងាររៀបចំនិងអនុវត្ត ផ.យ.អ.ជ.)

៣. ពង្រឹងកិច្ចសម្របសម្រួលរវាងស្ថាប័នកណ្តាលទាំងបួន (ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ)

ទិសដៅការងារទី៤៖ បន្តពង្រឹងកិច្ចសម្របសម្រួលនៅកម្រិតអន្តរក្រសួង និងអន្តរជាតិ ជាមួយដៃគូអភិវឌ្ឍន៍ តាមរយៈសកម្មភាពនានាដូចខាងក្រោម

១. បន្តចូលរួមនិងរួមចំណែក ក្នុងយន្តការអន្តរស្ថាប័នរបស់ រាជរដ្ឋាភិបាលកម្ពុជា
- ចូលរួមក្នុងការអភិវឌ្ឍបៃតង
- បន្តកិច្ចសហប្រតិបត្តិការវិនិយោគ (ច្រកចេញចូលតែមួយ)
- បន្តកិច្ចសហប្រតិបត្តិការ តាមរយៈយន្តការក្រុមប្រឹក្សា ក្រុមការងារបច្ចេកទេស នានា

២. ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយនឹងដៃគូអភិវឌ្ឍន៍នានា

៣. បន្តពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-វៀតណាម

៤. បន្តចូលរួមក្នុងការងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ពាណិជ្ជកម្មតាមព្រំដែនកម្ពុជាវៀតណាម

៥. បន្តចូលរួមក្នុងសកម្មភាពការងារកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម

៦. បន្តចូលរួមក្នុងសកម្មភាពការងារអាស៊ាន

## ២.២ សម្រាប់វិទ្យាស្ថានជាតិស្ថិតិ

ទិសដៅការងារទី៥៖ សម្របសម្រួល និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធស្ថិតិជាតិ និងសមត្ថភាពស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ

១. បន្តពង្រឹងអភិបាលកិច្ចស្ថិតិ
- វិសោធនកម្មច្បាប់ស្ថិតិ និងអនុក្រឹត្យ
- ពង្រឹងការអនុវត្តក្របខណ្ឌបទប្បញ្ញត្តិស្ថិតិ
- រៀបចំធ្វើផែនការមេស្ថិតិបច្ចុប្បន្នកម្ម ២០១៦-២០២៥
- អភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

២. បន្តធ្វើអោយប្រសើរឡើងនូវការសម្របសម្រួលទូទាំងប្រព័ន្ធស្ថិតិ
- កិច្ចប្រជុំក្រុមប្រឹក្សាស្ថិតិ (SAC)
- កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ (SCC)

- ➢ ប្រជុំក្រុមការងារបច្ចេកទេសស្ថិតិតាមផ្នែក (កាំអ៊ិនហ្វូ, បទប្បញ្ញតិស្ថិតិ ។ល។)
- ➢ រៀបចំនិងអនុវត្តចំណាត់ថ្នាក់ស្តង់ដារស្ថិតិជាតិ(CSOC)

៣. បន្តកសាងសមត្ថភាពស្ថាប័នវិទ្យាស្ថានជាតិស្ថិតិ

- ➢ បណ្តុះបណ្តាលរយៈពេលមធ្យមនិងវែងក្នុងនិងក្រៅប្រទេស
- ➢ ទស្សនៈកិច្ចសិក្សា ប្រជុំ និងសិក្ខាសាលាក្រៅប្រទេស
- ➢ ពង្រឹងសមត្ថភាពផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យាតាមរយៈការបណ្តុះបណ្តាល សិក្ខាសាលា និង កិច្ចសហប្រតិបត្តការអន្តរជាតិ
- ➢ សហប្រតិបត្តិការអន្តរជាតិ

## ទិសដៅការងារទី៦៖ សម្របសម្រួលនិងកែលម្អប្រព័ន្ធស្ថិតិជាតិនិងសមត្ថភាពស្ថាប័នរបស់វិទ្យាស្ថានជាតិស្ថិតិ

| | ៦.១.១៨ ធ្វើឱ្យប្រសើរឡើងលើការត្រៀម លទ្ធភាពមាន និងផ្សព្វផ្សាយ ការស្រាវជ្រាវនិងការអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ២០ ០០០ | | |

| ធាតុចេញសំខាន់ៗ របស់វិទ្យាស្ថានជាតិស្ថិតិ | ផែនការសកម្មភាព | ពេលវេលាសម្រាប់អនុវត្ត | | | | តម្រូវការការគាំទ្រ | | សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | ត្រី.១ | ត្រី.២ | ត្រី.៣ | ត្រី.៤ | តម្លៃ[3] | ប្រភព | |
| | ▪ ធ្វើការស្រាវជ្រាវលើបញ្ហាស្ថិតិសង្គម | ✓ | ✓ | ✓ | ✓ | ១០ ០០០ | | |
| | ▪ ធ្វើការស្រាវជ្រាវលើបញ្ហាស្ថិតិសេដ្ឋកិច្ច | ✓ | ✓ | ✓ | ✓ | ១០ ០០០ | | |
| | ៦.១.១៩ ចងក្រង និងបោះពុម្ពនូវសៀវភៅស្ថិតិប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ | ២ ០០០ | | |
| | ៦២. ការកសាងសមត្ថភាពស្ថាប័ន | | | | | | | |
| | ៦.២.១ បុគ្គលិកពាក្រុមរបស់វិទ្យាស្ថានជាតិស្ថិតិនិងក្រសួងពាក់ព័ន្ធត្រូវចូលរួមបណ្តុះបណ្តាលវគ្គស្ថិតិមូលដ្ឋាន | ✓ | ✓ | ✓ | ✓ | ១៥០ ០០០ | | |
| | ▪ បុគ្គលិកពា៥នាក់ពីវិទ្យាស្ថានជាតិស្ថិតិនឹងចូលរួមវគ្គបណ្តុះបណ្តាលស្តីពីស្ថិតិមូលដ្ឋាន | ✓ | ✓ | ✓ | | ១៥ ០០០ | | |
| | ▪ បុគ្គលិកពា៥នាក់ពីក្រសួងពាក់ព័ន្ធនឹងចូលរួមវគ្គបណ្តុះបណ្តាលស្តីពីស្ថិតិមូលដ្ឋាន | | | ✓ | ✓ | ១៥ ០០០ | | |
| | ▪ បុគ្គលិកពា៥នាក់មកពីមន្ទីរផែនការ រាជធានី ខេត្តនឹងចូលរួមវគ្គបណ្តុះបណ្តាលពី ស្ថិតិមូលដ្ឋាន(២៤រាជធានី/ខេត្ត) | ✓ | ✓ | ✓ | ✓ | ១២០ ០០០ | | |
| | ៦.២.២ បុគ្គលិកពាក្រុមរបស់វិទ្យាស្ថានជាតិស្ថិតិនិងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវចូលរួមបណ្តុះបណ្តាលវគ្គស្ថិតិជាន់ខ្ពស់ | ✓ | ✓ | ✓ | ✓ | ១៥០ ០០០ | | |
| | ▪ បុគ្គលិកពា៥នាក់ ពី វិទ្យាស្ថានជាតិស្ថិតិនឹងត្រូវបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីស្ថិតិមូលដ្ឋាន | ✓ | ✓ | ✓ | ✓ | ១៥ ០០០ | | |
| | ▪ បុគ្គលិកពា៥នាក់ពីក្រសួងពាក់ព័ន្ធនឹងត្រូវបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីស្ថិតិមូលដ្ឋាន | ✓ | ✓ | ✓ | ✓ | ១៥ ០០០ | | |

| ធាតុចេញសំខាន់ៗ របស់ វិទ្យាស្ថានជាតិស្ថិតិ | ផែនការសកម្មភាព | ពេលវេលាសម្រាប់អនុវត្ត | | | | តម្រូវការការគាំទ្រ | | សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | ត្រី.១ | ត្រី.២ | ត្រី.៣ | ត្រី.៤ | តម្លៃ[3] | ប្រភព | |
| | ▪ បុគ្គលិក៣៥នាក់មកពីមន្ទីរខេត្តនឹងត្រូវបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីស្ថិតិជាមុន (២៤ខេត្ត) | ✓ | ✓ | ✓ | ✓ | ១២០ ០០០ | | |
| ការងារទី៧៖គោលនយោបាយ ផ្តល់ព័ត៌មាននិងការកើនឡើង នៃការប្រើប្រាស់ស្ថិតិផ្លូវការ | ៧.១ បង្កើនការទទួលបានស្ថិតិផ្លូវការ | | | | | | | |
| | ៧.១.១ ពង្រឹងឃ្លាំងទិន្នន័យស្ថិតិជាតិ | ✓ | ✓ | ✓ | ✓ | | | |
| | ៧.១.២ ធ្វើបច្ចុប្បន្នភាពទិន្នន័យមូលដ្ឋាន សូចនាករសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា (កាំអ៊ីនហ្វូជំនាន់ ២០១៤ផ្អែកលើDevInfoVersion 7.0) | ✓ | ✓ | ✓ | ✓ | ២០ ០០០ | UNICEF | |
| | ៧.១.៣ លើកកម្ពស់ការប្រើប្រាស់ប្រភពទិន្នន័យសម្រាប់អ្នកប្រើប្រាស់ ផ្ទៃក្នុងវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងស្ថាប័ននានាតាមប្រព័ន្ធ SuperSTAR (Off-Line, On-Line), SQL Server, CAMInfo (Off-Line, On-Line) និងមជ្ឈមណ្ឌលសេវាកម្មព័ត៌មានស្ថិតិ (DUSC) | ✓ | ✓ | ✓ | ✓ | | | |
| | ៧.១.៤ កែលំអរប្រព័ន្ធ (NADA) និង ចងក្រងឯកសារ ទិន្នន័យ (រួមបញ្ចូលបច្ចេកទេសនៃ NADA និង Toolkit)នៃ អង្កេត ជំរឿនថ្មីៗ ដើម្បីដាក់ចូល ទៅក្នុងប្រព័ន្ធ (NADA)តាមវេបសាយវិទ្យាស្ថានជាតិស្ថិតិ និងការបញ្ចូលទិន្នន័យក្នុងDVD/CD-ROM | ✓ | ✓ | ✓ | ✓ | ១៥ ០០០ | | |
| | ៧.១.៥ ការផលិតសៀវភៅផែនទីនៃជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៣ ដោយមានបង្ហាញទិន្នន័យលើផែនទី និងសូចនាករតាមតំបន់កសិកម្ម | ✓ | ✓ | ✓ | ✓ | ១០ ០០០ | | |
| | ▪ ភេទ និង អាយុ ភាពជាម្ចាស់កសិដ្ឋាន(ប្រុស ធៀបនិងស្រី) | | | | | | | |
| | ▪ ផ្ទៃដីសរុបរបស់កសិដ្ឋាន គិតជាហិកតា | | | | | | | |
| | ▪ ប្រភេទលិខិតស្នាមជាកម្មសិទ្ធិកសិដ្ឋាន | | | | | | | |

| ធាតុចេញសំខាន់ៗ របស់ វិទ្យាស្ថានជាតិស្ថិតិ | ផែនការសកម្មភាព | ពេលវេលាសម្រាប់អនុវត្ត | | | | តម្រូវការការគាំទ្រ | | សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | ត្រី.១ | ត្រី.២ | ត្រី.៣ | ត្រី.៤ | តម្លៃ[3] | ប្រភព | |
| | ▪ ដំណាំរយៈពេលខ្លី រយៈពេលវែង ជុំវិញផ្ទះ | | | | | | | |
| | ▪ គោលបំណងចម្បងនៃផលិតកម្ម (លក់ឬប្រើប្រាស់ក្នុងគ្រួសារ) | | | | | | | |
| | ▪ បសុសត្វ/បសុបក្សី ក្នុងកសិដ្ឋាន ឬតាមផ្ទះ | | | | | | | |
| | ▪ ការធ្វើវារីវប្បកម្ម | | | | | | | |
| | ▪ ព័ត៌មានសមាជិកគ្រួសារ ដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចការអប់រំ តាមភេទ និងក្រុមអាយុ (ប្រុស ធៀបនិងស្រី) | | | | | | | |
| | ៧.១.៦ ធ្វើបច្ចុប្បន្នភាពCensusInfo Version 2.0 | ✓ | ✓ | ✓ | ✓ | ១៥១៣៩ | RGC/UNFPA | |
| | ៧.១.៧ ផលិតតួលេខស្ថិតិ (Statistical Figure)សម្រាប់ថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ៥000 | RGC/UNFPA | |
| | ៧.១.៨ ដំណើរការគូសផែនទីជំរឿន មាតប្រព័ន្ធ GPS | | | | | | | |
| | **៧.២ បង្កើនការយល់ដឹងស្ដីពីទិន្នន័យស្ថិតិនិងការប្រើប្រាស់និង រួមបញ្ចូលចំណេះដឹង ស្ដីពីគោលនយោបាយអភិវឌ្ឍន៍ការកំណត់ចំណុចដៅ និងការធ្វើអាទិភាព** | | | | | | | |
| | ៧.២.១ បង្កើនការប្រើប្រាស់ និងផ្សព្វផ្សាយទិន្នន័យស្ថិតិដល់បណ្ដាក្រសួង ស្ថាប័ន និងអង្គភាពនានា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | | | |
| | ៧.២.២ បណ្ដុះបណ្ដាលមន្ត្រីតាមបណ្ដាក្រសួងស្ថាប័ន រាជធានី ខេត្តនិង អង្គការក្រៅរដ្ឋាភិបាលនានា អំពីការប្រើប្រាស់កម្មវិធី CAMInfo (Off-Line, On-Line)បង្កើតទិន្នន័យមូលដ្ឋានកាំអ៊ីនហ្វូ និងបង្កើត Data fact sheet តាមរយៈកាំអ៊ីហ្វូOff-Line, On-Line | ✓ | ✓ | ✓ | ✓ | ១០ 000 | | |

## តារាងម៉ាទ្រីសផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤ ទី៣÷ ការងាររួម

| ធាតុចេញសំខាន់ៗ របស់អគ្គនាយកដ្ឋានផែនការ | សកម្មភាព | ពេលវេលាសម្រាប់អនុវត្ត | | | | តម្រូវការគាំទ្រ | | សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | ត្រី.១ | ត្រី.២ | ត្រី.៣ | ត្រី.៤ | តម្លៃ[4] | ប្រភព | |
| ការងារទី៨៖ រៀបចំផែនការយុទ្ធសាស្ត្រក្រសួងផែនការ | ៨.១ វាយតម្លៃពីលទ្ធផលនៃការអនុវត្ត *ផយផក បច្ចុប្បន្នកម្ម ២០០៩-២០១៣* និងរៀបចំ *ផយផក ២០១៤-២០១៨ និងផែនការប្រតិបត្តិឆ្នាំ២០១៤* | | | | | | | |
| | ៨.១.១ រៀបចំ និងបោះពុម្ព *ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផ.យ.ផ.ក.) ២០១៤-២០១៨* | | | | | | UNFPA, UNICEF | |
| | ▪ បញ្ចប់ការរៀបចំ *ផ.យ.ផ.ក. ២០១៤-២០១៨* និងសុំការអនុម័តពីថ្នាក់ដឹកនាំក្រសួងផែនការ | ✓ | | | | | | |
| | ▪ បោះពុម្ព *ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផ.យ.ផ.ក.) ២០១៤-២០១៨* ដែលបានការអនុម័តពីថ្នាក់ដឹកនាំក្រសួង | ✓ | | | | | UNFPA, UNICEF | |
| | ៨.១.៣ រៀបចំ និងបោះពុម្ព ផែនការប្រតិបត្តិប្រចាំឆ្នាំនៃ *ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផ.យ.ផ.ក.)* | | | | | | UNFPA, UNICEF | |
| | ▪ បញ្ចប់ការរៀបចំ *ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤* នៃ *ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផ.យ.ផ.ក.) ២០១៤-២០១៨* និងសុំការអនុម័តពីថ្នាក់ដឹកនាំក្រសួងផែនការ | ✓ | | | | | | |
| | ▪ បោះពុម្ព *ផែនការប្រតិបត្តិប្រចាំឆ្នាំនៃផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផ.យ.ផ.ក.) ២០១៤-២០១៨* ដែលបានការអនុម័តពីថ្នាក់ដឹកនាំក្រសួង | ✓ | | | | | | |

[4] តម្លៃប៉ាន់ស្មានគិតជា ដុល្លារអាមេរិក

| ធាតុចេញសំខាន់ៗ របស់អគ្គនាយកដ្ឋានផែនការ | សកម្មភាព | ពេលវេលាសម្រាប់អនុវត្ត | | | | តម្រូវការគាំទ្រ | | សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | ត្រី.១ | ត្រី.២ | ត្រី.៣ | ត្រី.៤ | តម្លៃ[4] | ប្រភព | |
| | ៨.១.៤ ស្វែងរកការគាំទ្រផ្នែក ថវិកា និងសម្ភារបរិក្ខា សម្រាប់អនុវត្តគម្រោង សកម្មភាព របស់ក្រសួងផែនការ | ✓ | ✓ | ✓ | ✓ | | UNFPA, UNICEF, and UNDP | |
| **ការងារទី៩ : ពង្រឹងកិច្ចសម្របសម្រួលផ្ដល់ការវិវឌ្ឍ អន្តរភាពពាក់ព័ន្ធ ទាំងអស់ របស់ក្រសួងផែនការ ក្នុងការអនុវត្តយុទ្ធសាស្ត្រអន្តរវិស័យនានា របស់រាជរដ្ឋាភិបាលកម្ពុជា** | **៩.១ ពង្រឹងការបញ្ជ្រាបយេនឌ័រ នៅក្នុងប្រព័ន្ធការងារផែនការ និងស្ថិតិ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | | | | | | | |
| | ៩.១.១ ការរៀបចំ និងបោះពុម្ព *ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្រសួងផែនការ ២០១៤-២០១៨* | | | | | | UNFPA | |
| | ▪ ត្រូវការជំនាញការបរទេស ដើម្បី វាយតម្លៃពីលទ្ធផលនៃការអនុវត្ត *ផយបយផក បច្ចុប្បន្នកម្ម ២០០៩-២០១៣* និងរៀបចំ *ផយបយផក ២០១៤-២០១៨* | ✓ | | | | | | |
| | ▪ បោះពុម្ពនិងផ្សព្វផ្សាយ *ផយបយផក ២០១៤-២០១៨* | ✓ | | | | | | |
| | ៩.១.៣ បន្តពង្រឹងការងារបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិនៅថ្នាក់ជាតិ | | | | | | UNFPA | |
| | ▪ កែសម្រួលឯកសារមូលដ្ឋានស្តីពី យេនឌ័រនិងការបញ្ជ្រាបយេនឌ័រ សម្រាប់បណ្តុះបណ្តាលដល់ និស្សិតនៅមជ្ឈមណ្ឌលបណ្តុះបណ្តាល ផែនការនិងស្ថិតិ និង រៀបចំឯកសារកម្រិតខ្ពស់ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ សម្រាប់ការបណ្តុះបណ្តាលមន្ត្រីក្រសួងផែនការ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | ✓ | | | | | | |
| | ▪ ត្រូវការជំនាញការបរទេសម្នាក់ដើម្បីរៀបចំឯកសារណែនាំកម្រិតខ្ពស់ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ | ✓ | | | | | | |

| ធាតុចេញសំខាន់ៗ របស់អង្គភាពអនុវត្ត | សកម្មភាព | ពេលវេលាសម្រាប់អនុវត្ត | | | | តម្រូវការគាំទ្រ | | សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | ត្រី.១ | ត្រី.២ | ត្រី.៣ | ត្រី.៤ | តម្លៃ[4] | ប្រភព | |
| | ▪ រៀបចំបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ ដល់មន្ត្រីបង្គោល ដើម្បីជាមូលដ្ឋានធ្វើការបណ្តុះបណ្តាលបន្ត។ | | ✓ | | | | | |
| | ▪ ផ្តល់ការបណ្តុះបណ្តាលពី យេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងអនុសញ្ញា ស៊ី-ដ ដល់និស្សិតនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការនិងស្ថិតិ | | ✓ | ✓ | | | | |
| | ▪ ផ្តល់ការបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រក្នុងផែនការនិងស្ថិតិ ដល់មន្ត្រីក្រសួងផែនការថ្នាក់ជាតិ | | ✓ | ✓ | | | | |
| | ▪ ផ្តល់ការបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រកម្រិតខ្ពស់ក្នុងផែនការនិងស្ថិតិ ដល់មន្ត្រីក្រសួងផែនការថ្នាក់ក្រោមជាតិ | | ✓ | ✓ | | | | |
| | ៩.១.៤ រៀបចំកិច្ចប្រជុំ ដើម្បីត្រួតពិនិត្យ លទ្ធផលនៃការបញ្ជ្រាបយេនឌ័រក្នុងការងារផែនការនិងស្ថិតិ នៅថ្នាក់ក្រោមជាតិ (ក្រោយពីការទទួលបានការបណ្តុះបណ្តាល) | ✓ | ✓ | ✓ | ✓ | | UNFPA | |
| | ៩.១.៥ បន្តសកម្មភាពរៀបចំចងក្រងស្ថិតិយេនឌ័រ | | | | | | | |
| | ▪ បន្តផ្សព្វផ្សាយពីកូនសៀវភៅ ស្តីពី ស្ត្រីនិងបុរស នៅកម្ពុជា | ✓ | | | | | SIDA | |
| | ▪ រៀបចំទស្សនកិច្ចសិក្សាពីការចងក្រងស្ថិតិយេនឌ័រ នៅប្រទេស ស៊ុយអែត ឬជប៉ុន | | | ✓ | | | SIDA | |
| | ៩.១.៦ បង្កើនការប្រើប្រាស់ទិន្នន័យនិងព័ត៌មានបំបែកតាមភេទ(យេនឌ័រប្រជាជនតាមតំបន់)។ | ✓ | ✓ | ✓ | ✓ | | | |

| ធាតុចេញសំខាន់ៗ របស់អគ្គនាយកដ្ឋានផែនការ | សកម្មភាព | ពេលវេលាសម្រាប់អនុវត្ត | | | | តម្រូវការគាំទ្រ | | សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | ត្រី.១ | ត្រី.២ | ត្រី.៣ | ត្រី.៤ | តម្លៃ[4] | ប្រភព | |
| | ៩.២ ការចូលរួមចំណែកទប់ស្កាត់ ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ក្នុងក្របខ័ណ្ឌនៃក្រុមប្រឹក្សាគោលនយោបាយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | | | | | | | |
| | ៩.២.១ បន្តពង្រឹងគណៈកម្មាធិការអេដស៍ក្រសួងផែនការក្នុងការស្វែងយល់ និងរួមចំណែកទប់ស្កាត់ ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជា | ✓ | ✓ | ✓ | ✓ | | | |
| | ៩.២.២ បន្តតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីការបង្ការនិងទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជា | ✓ | ✓ | ✓ | ✓ | | | |
| | ៩.២.៣ បន្តពង្រឹងសមត្ថភាពរបស់មន្ត្រីក្រសួងផែនការ និងបណ្តុះបណ្តាលដល់និស្សិតនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការនិងស្ថិតិ ស្តីពីការយល់ដឹង និងការបង្ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ | ✓ | ✓ | ✓ | ✓ | | | |
| | ៩.២.៤ រៀបចំរបាយការណ៍ប្រចាំ ត្រីមាស ឆមាស ៩ខែដើមឆ្នាំ និងប្រចាំឆ្នាំ ទៅក្រុមប្រឹក្សាគោលនយោបាយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | ✓ | ✓ | ✓ | ✓ | | | |
| | ៩.៣ ពង្រឹងការចូលរួមរបស់មន្ត្រីក្រសួងការ ក្នុងក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងផែនការ ក្នុងក្របខ័ណ្ឌកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ✓ | ✓ | ✓ | ✓ | | | |
| | ៩.៤ បន្តកិច្ចសហប្រតិបត្តិការជាមួយនឹងបណ្តាប្រទេសសមាជិកអាស៊ាន និង ជាមួយនឹងបណ្តាប្រទេស នៃមហាអនុតំបន់ទន្លេមេគង្គ ក្នុងការងារផែនការនិងស្ថិតិ | ✓ | ✓ | ✓ | ✓ | | MCR | |

| ធាតុចេញសំខាន់ៗ របស់អគ្គនាយកដ្ឋានផែនការ | សកម្មភាព | ពេលវេលាសម្រាប់អនុវត្ត | | | | តម្រូវការគាំទ្រ | | សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | ត្រី.១ | ត្រី.២ | ត្រី.៣ | ត្រី.៤ | តម្លៃ[4] | ប្រភព | |
| | ៩.៥ រៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ សម្រាប់ប្រើប្រាស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | | | | | UNFPA, UNICEF, and UNDP | |
| | ▪ រៀបចំសេចក្តីណែនាំបច្ចេកទេសសម្រាប់បង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិ | | ✓ | ✓ | ✓ | | | |
| | ▪ បង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិ | | ✓ | ✓ | ✓ | | | |
| | ▪ រៀបចំឯកសារណែនាំពីការប្រើប្រាស់ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិ | | ✓ | ✓ | ✓ | | | |
| | ៩.៦ បន្តពង្រឹងការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ *ផ.យ.អ.ជ.* | | | | | | | |
| | ៩.៦.១ ការពង្រឹងការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដោយផ្អែកលើលទ្ធផល នៅក្រសួងផែនការ និង តាមវិស័យ | | | | | | UNFPA, UNICEF, UNDP, and ADB | |
| | ▪ ដំណើរការសិក្ខាសាលា *ក្រុមការងារជាតិក្រុមការងាររងជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ.* | | ✓ | ✓ | ✓ | | | |
| | ▪ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រមូលទិន្នន័យ សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ | | ✓ | | ✓ | | | |
| | ▪ រៀបចំវេទិកា ស្តីពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន NGOs និងជំនាញការដែលមានបទពិសោធន៍ពីបរទេស។ | | ✓ | ✓ | | | | |

| ធាតុចេញសំខាន់ៗ របស់អគ្គនាយកដ្ឋានផែនការ | សកម្មភាព | ពេលវេលាសម្រាប់អនុវត្ត | | | | តម្រូវការគាំទ្រ | | សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | ត្រី.១ | ត្រី.២ | ត្រី.៣ | ត្រី.៤ | តម្លៃ[4] | ប្រភព | |
| | ▪ រៀបចំទស្សនកិច្ចសិក្សា ពីការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យ នៅបណ្ដាប្រទេសដែលមានបទពិសោធន៍ និងទទួលបានជោគជ័យ លើការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ | | ✓ | ✓ | | | | |
| | ៩.៦.២ រៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីចំណេះដឹងស្ដីពីមូលដ្ឋានស្ថិតិមូលដ្ឋាន ដំណាក់កាលទី២ ដល់មន្ត្រីក្រសួងផែនការ និងក្រសួងស្ថាប័នពាក់ព័ន្ធ | ✓ | ✓ | | | | UNICEF | |
| | ៩.៦.៣ ធ្វើបច្ចុប្បន្នភាពនីតិវិធីសម្រាប់រួមចំណែក តាមដានត្រួតពិនិត្យ ផ.យ.អ.ជ./គ.អ.ស.ក. ដោយប្រើប្រាស់កម្មវិធីកាំអ៊ិនហ្វូ | ✓ | ✓ | ✓ | ✓ | | UNICEF | |

# ឧបសម្ព័ន្ធ ១៖ អង្គការលេខរបស់ក្រសួងផែនការ



# ឧបសម្ព័ន្ធ ២

## អនុក្រឹត្យលេខ ៥៥ អនក្រ.បក
## ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងផែនការ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ៥៥ អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពី**

**ការរៀបចំ និង ការប្រព្រឹត្តទៅ**

**របស់ក្រសួងផែនការ**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៧

## សម្រេច :

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ :** អនុក្រឹត្យនេះរៀបចំអង្គភាពនានារបស់ក្រសួងផែនការ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃបណ្តាអគ្គនាយកដ្ឋាន និង នាយកដ្ឋាននានា ។

## ជំពូក ២

## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា ២ :** ក្រសួងផែនការត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់ឱ្យទទួលបន្ទុកបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យផែនការស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងលើការអនុវត្តស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ :** ក្រសួងផែនការមានមុខងារនិងភារកិច្ចដូចតទៅ :

- ធ្វើសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ ទស្សនាទាន យុទ្ធសាស្ត្រ គោលនយោបាយ និងកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិដោយឈរលើមូលដ្ឋាននៃការបង្កើតឱ្យមាននិរន្តរភាព និង តុល្យភាពរវាង កិច្ចអភិវឌ្ឍ និង សមភាព យុត្តិធម៌ក្នុងសង្គម រវាង កិច្ចអភិវឌ្ឍខាងសេដ្ឋកិច្ច និងកិច្ចអភិវឌ្ឍខាងសង្គមកិច្ចនិងវប្បធម៌ រវាងទីក្រុងនិងជនបទ រវាងការធ្វើអាជីវកម្មនិងការកកើតឡើងវិញនៃធនធានធម្មជាតិ និងរវាង កិច្ចអភិវឌ្ឍនិងការការពារបរិស្ថាន ។
- ដឹកនាំនិងគ្រប់គ្រងវិធីសាស្ត្រ និងបែបបទក្នុការរៀបចំផែនការ ស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចតាមប្រព័ន្ធវិមជ្ឈការក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- រៀបចំផែនការ និងកម្មវិធីជាតិសម្រាប់កិច្ចអភិវឌ្ឍរយៈពេលវែង មធ្យម និងរយៈពេលខ្លីដោយសម្របសម្រួលជាមួយបណ្តាក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីឱ្យផែនការនិងកម្មវិធីជាតិទាំងនោះស៊ីសង្វាក់គ្នារវាងបណ្តាផ្នែកនិងសាខាសេដ្ឋកិច្ច-សង្គមកិច្ច ព្រមទាំងខេត្ត-ក្រុង និងតំបន់នានាក្នុងក្របខ័ណ្ឌ ទូទាំងប្រទេស ។

- តាមដានត្រួតពិនិត្យ ការអនុវត្ត ផែនការ កម្មវិធីជាតិ និងបណ្តាគម្រោងពីគ្រប់ផ្នែកទាំងអស់ ហើយវាយតំលៃលទ្ធផលនៃការអនុវត្ត
និងលើកឡើងពីវិធានការកែតម្រូវផែនការកម្មវិធីជាតិទាំងនោះក្នុងករណីចាំបាច់ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំ យុទ្ធសាស្ត្រ គោលនយោបាយ និងកំណត់អាទិភាពក្នុងការវិនិយោគទាំងឯកជន និងសាធារណៈ ដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពនូវសក្តានុពលនៃប្រភពធនធានទាំងក្នុង និងក្រៅប្រទេស ។
- សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីកំណត់និងបែងចែកទុនវិនិយោគសាធារណៈប្រចាំឆ្នាំ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំយុទ្ធសាស្ត្រគោលនយោបាយ និងកំណត់អាទិភាពក្នុងផែនការសហប្រតិបត្តិការសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌និងវិទ្យាសាស្ត្របច្ចេកទេសជាមួយបរទេស ឱ្យស៊ីសង្វាក់គ្នាជាមួយនឹងទិសដៅនិងគោលនយោបាយអភិវឌ្ឍន៍ជាតិ ។
- រួមជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំគោលនយោបាយប្រជាសាស្ត្រ និងផែនការសកម្មភាពស្តីពី ការបែងចែកកំលាំងពលកម្មសង្គមឱ្យមានតុល្យភាព ធានាដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចនិងការពារជាតិ ។
- ធ្វើការអង្កេត និងការសិក្សាស្រាវជ្រាវដែលចាំបាច់ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។
- គ្រប់គ្រងព័ត៌មានស្ថិតិសេដ្ឋកិច្ច-សង្គមកិច្ច និងប្រជាសាស្ត្រក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- គ្រប់គ្រងប្រព័ន្ធស្ថិតិជាតិកម្ពុជាតាមការចងក្រង ណែនាំអនុវត្តវិធីប្រើចំណាត់ថ្នាក់ស្ថិតិនិងគំរូតារាងឯកភាពក្នុងការបំពេញនិងការប្រមូលយកព័ត៌មានស្ថិតិ ណែនាំអនុវត្តវិធីសាស្ត្រ និងរូបមន្តគណនាទិន្នន័យស្ថិតិឯកភាពក្នុងទូទាំងប្រទេស ។
- រៀបចំវិធីសាស្ត្រធ្វើជំរឿន ធ្វើអង្កេត និងអនុវត្តការធ្វើជំរឿន ការធ្វើអង្កេតប្រជារាស្ត្រសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ។
- ផ្តល់ជំនួយខាងផ្នែកបច្ចេកទេសនិងវិធីសាស្ត្រ ឬអនុវត្តការធ្វើជំរឿននិងអង្កេតក្នុងវិស័យ និងប្រធានបទនានាតាមសំណូមពររបស់អ្នកប្រើប្រាស់ទិន្នន័យស្ថិតិ ។
- ចងក្រងគណនេយ្យជាតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវាកម្ម និងកម្រងតួលេខស្ថិតិរបស់កម្ពុជាទៀងទាត់ជាប្រចាំ ។
- សហការដោះដូរព័ត៌មានជាមួយអង្គភាពស្ថិតិជាតិនៃប្រទេសក្នុងតំបន់ក្នុងពិភពលោក និងបណ្តាអង្គការជាតិ អង្គការអន្តរជាតិ ។
- បំពេញមុខងារនិងភារកិច្ចចាំបាច់ផ្សេងទៀតតាមការទុកចិត្តនិងការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ។

**មាត្រា ៤** :ក្រសួងផែនការមានរចនាសម្ព័ន្ធដូចតទៅ :

**ក. នៅថ្នាក់កណ្តាល**

- អគ្គនាយកដ្ឋានផែនការរួមមាន :

- ❖ នាយកដ្ឋានផែនការទូទៅ
- ❖ នាយកដ្ឋានផែនការសេដ្ឋកិច្ច
- ❖ នាយកដ្ឋានផែនការសង្គមកិច្ច
- ❖ នាយកដ្ឋានផែនការវិនិយោគ
- ❖ នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

- វិទ្យាស្ថានជាតិស្ថិតិដែលមានឋានានុក្រមស្មើថ្នាក់អគ្គនាយកដ្ឋានរួមមាន:
  - ❖ នាយកដ្ឋានស្ថិតិទូទៅ
  - ❖ នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច
  - ❖ នាយកដ្ឋានស្ថិតិសង្គមកិច្ច
  - ❖ នាយកដ្ឋានប្រជាសាស្ត្រ ជំរឿន និងអង្កេត
- អគ្គាធិការដ្ឋាន
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានរដ្ឋបាលទូទៅ
- នាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញវត្ថុ

**ខ. អង្គភាពមូលដ្ឋាន**

- មន្ទីរផែនការខេត្ត ក្រុង ។

អង្គការលេខរបស់ក្រសួងផែនការ មានភ្ជាប់ក្នុងឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូក ៣

## អគ្គនាយកដ្ឋានផែនការ

**មាត្រា ៥** :អគ្គនាយកដ្ឋានផែនការមានមុខងារអនុវត្តនូវរាល់បេសកកម្មរបស់ក្រសួងក្នុងការ :

- ធានាភាពស៊ីសង្វាក់គ្នាក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ដោយសម្របសម្រួលផែនការ កម្មវិធីនិងគម្រោងអភិវឌ្ឍន៍តាមផ្នែកនិងសាខាសេដ្ឋកិច្ច ដែលរៀបចំឡើងដោយបណ្តាក្រសួង-រដ្ឋលេខាធិការដ្ឋានស្ថាប័នដែលពាក់ព័ន្ធ និងខេត្ត-ក្រុង ។
- តាមដានត្រួតពិនិត្យការអនុវត្តផែនការ និងកម្មវិធីជាតិ ដោយសហការជាមួយក្រសួង រដ្ឋលេខាធិការដ្ឋានស្ថាប័នដែលពាក់ព័ន្ធ និងខេត្ត-ក្រុង ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនរដ្ឋមន្ត្រីដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ សម្រេច ។

- រៀបចំរបាយការណ៍ស្តីពីសភាពការណ៍សេដ្ឋកិច្ច-សង្គមកិច្ច ប្រចាំត្រីមាសទី១ ឆមាសទី១ ៩ខែដើមឆ្នាំ និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដោយសម្របសម្រួលជាមួយក្រសួងរដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ ខេត្ត ក្រុង និងវិទ្យាស្ថានជាតិស្ថិតិ ។

អគ្គនាយកដ្ឋានផែនការត្រូវដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានផែនការមាននាយកដ្ឋានចំណុះចំនួន ៥ ដូចខាងក្រោម ហើយនាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

**មាត្រា ៦ :នាយកដ្ឋានផែនការទូទៅ**ទទួលបន្ទុក :

- កសាងទស្សនទាន យុទ្ធសាស្ត្រផែនការនិងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចជាតិរយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយសម្របសម្រួលជាមួយនាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋានផែនការ
- វិភាគនិងព្យាករណ៍ពីស្ថានភាពរួមនៃការវិវត្ត ខាងផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅក្នុងប្រទេស ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ ដើម្បីកែតម្រង់ទិសដៅនៃការអភិវឌ្ឍប្រទេស ឱ្យបានទាន់ពេលវេលា ។
- រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ចរួមមានគណនេយ្យជាតិ សារពើពន្ធ ជញ្ជីងទូទាត់ រូបិយវត្ថុ និងស្ថាប័នហិរញ្ញវត្ថុ ។

**មាត្រា ៧ :នាយកដ្ឋានផែនការសេដ្ឋកិច្ច**ទទួលបន្ទុក :

- វិភាគនិងព្យាករណ៍អំពីស្ថានភាពរួម នៃការវិវត្តខាងផ្នែកសេដ្ឋកិច្ចនានានៅក្នុងប្រទេស ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ដើម្បីកែតម្រង់ទិដៅនៃការអភិវឌ្ឍប្រទេស ឱ្យបានទាន់ពេលវេលា។
- រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យសេដ្ឋកិច្ចនានារួមមានជាអាទិ៍ កសិកម្ម រុក្ខាកម្ម នេសាទ ឧស្សាហកម្ម គមនាគមន៍ ដឹកជញ្ជូន ពាណិជ្ជកម្ម ទេសចរណ៍ សំណង់ និងបរិស្ថាន ។

**មាត្រា ៨ :នាយកដ្ឋានផែនការសង្គមកិច្ច**ទទួលបន្ទុក :

- វិភាគនិងព្យាករណ៍អំពីស្ថានភាពរួមនៃការវិវត្តខាងផ្នែកសង្គមកិច្ចនិងស្ថានភាពប្រជាសាស្ត្រ នៅក្នុងប្រទេស ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ដើម្បីកែតម្រង់ទិសដៅនៃការអភិវឌ្ឍ ឱ្យបានទាន់ពេលវេលា ។
- រៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការក្នុងវិស័យសង្គមកិច្ចរួមមាន ការងារប្រជាសាស្ត្រ អប់រំបណ្តុះបណ្តាល អភិវឌ្ឍន៍ធនធានមនុស្ស អភិវឌ្ឍន៍សហគមន៍ ការកាត់បន្ថយភាពក្រីក្រ ផ្ទះសំបែង សុខាភិបាល អាហារូបត្ថម្ភ សង្គមកិច្ច-ការងារ វប្បធម៌ តួនាទីបុរសស្ត្រី សាសនា និងព័ត៌មាន ។

**មាត្រា ៩ :នាយកដ្ឋានផែនការវិនិយោគទទួលបន្ទុក :**

- វិភាគនិងព្យាករណ៍អំពី ស្ថានភាពរួមនៃការវិវត្ត ខាងផ្នែកវិនិយោគនៅក្នុងប្រទេស ទាំងវិនិយោគសាធារណៈ និងឯកជន ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ ដើម្បីតម្រង់ទិសវិនិយោគឱ្យសមស្របតាមទិសដៅនៃការអភិវឌ្ឍប្រទេស ។
- រៀបចំយុទ្ធសាស្ត្រវិនិយោគរយៈពេលខ្លី មធ្យម និងវែង ។
- កំណត់អាទិភាពក្នុងការបែងចែកទុនតាមវិស័យ ។
- ពិនិត្យសេចក្តីព្រាងគម្រោងវិនិយោគសាធារណៈរបស់បណ្តាក្រសួងនិងស្ថាប័ននានា ។
- រៀបចំកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ ។
- ចូលរួមក្នុងគណៈកម្មការដេញថ្លៃលើគ្រប់គម្រោងការងារវិនិយោគសាធារណៈ ។
- តាមដាននិងវាយតំលៃលទ្ធផលនៃការអនុវត្តន៍កម្មវិធីវិនិយោគសាធារណៈ ។

**មាត្រា ១០ :នាយកដ្ឋានទំនាក់ទំនងអន្តរជាតិទទួលបន្ទុក :**

- វិភាគនិងព្យាករណ៍ពីស្ថានភាពរួមនៃការងារសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយបរទេស អង្គការអន្តរ-ជាតិ និងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងលើកឡើងនូវយោបល់និងវិធានការចាំបាច់ ដើម្បីតម្រង់ទិសការងារសហប្រតិបត្តិការសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌និងវិទ្យាសាស្ត្របច្ចេកទេស ជាមួយបរទេសឱ្យស្របតាមទិសដៅនៃការអភិវឌ្ឍន៍ប្រទេស ។
- ធ្វើសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មាន និងសម្របសម្រួលក្នុងក្រុមខ័ណ្ឌការងារផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចជាមួយបរទេសតាមការចាំបាច់ ។
- សម្របសម្រួលការងារសហប្រតិបត្តិការសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌និងវិទ្យាសាស្ត្របច្ចេកទេសជាមួយបរទេសផ្សេងទៀតតាមការចាំបាច់ និងតាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល ជាអាទិ៍ដូចជា ការងារ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងបណ្តាប្រទេសក្នុងអនុតំបន់វិសាលភាពទន្លេមេគង្គ ជាដើម ។

## ជំពូក ៤

## វិទ្យាស្ថានជាតិស្ថិតិ

**មាត្រា ១១ :** វិទ្យាស្ថានជាតិស្ថិតិមានមុខងារ :

- អនុវត្តរាល់បេសកកម្មរបស់ក្រសួងក្នុងការធ្វើជំរឿន អង្កេតអំពី សេដ្ឋកិច្ច-សង្គមកិច្ចនិងប្រជាសាស្ត្រ ។ ចងក្រងនិងណែនាំវិធីប្រើប្រាស់ចំណាត់ថ្នាក់ស្ថិតិ តារាងឯកភាព និងវិធីសាស្ត្រគណនាទិន្នន័យស្ថិតិប្រមែប្រមូល ចងក្រងនិងផ្សព្វផ្សាយទិន្នន័យស្ថិតិស្តីពី ស្ថានភាពនៃការវិវត្តក្នុងផ្នែកសេដ្ឋកិច្ច សង្គមកិច្ចនៅក្នុងប្រទេស ។

- សហការជាមួយអង្គភាពស្ថិតិជាតិនៃប្រទេសនានាក្នុងតំបន់ និងពិភពលោក ក្នុងការដោះដូរព័ត៌មានស្ថិតិ បណ្តុះបណ្តាលមន្ត្រីជំនាញការងារស្ថិតិដើម្បីការអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិកម្ពុជា។ វិទ្យាស្ថានជាតិស្ថិតិត្រូវដឹកនាំដោយអគ្គនាយកមួយរូប ដែលតែងតាំងដោយព្រះរាជក្រឹត្យ និងនាយករងមួយចំនួនជួយធ្វើការតាមការចាំបាច់។
- វិទ្យាស្ថានជាតិស្ថិតិមាននាយកដ្ឋានចំណុះចំនួន ៤ ដូចខាងក្រោម ហើយនាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

**មាត្រា ១២ : នាយកដ្ឋានស្ថិតិទូទៅ** ទទួលបន្ទុក :

- សម្របសម្រួលទិន្នន័យស្ថិតិជាមួយនាយកដ្ឋាននានាចំណុះវិទ្យាស្ថានជាតិស្ថិតិ ដើម្បីចងក្រងចេញនូវគណនេយ្យជាតិរបស់កម្ពុជា ។
- ប្រមូលយកព័ត៌មានអំពីថ្លៃទំនិញប្រើប្រាស់ និងសេវា តាមកាលកំណត់ និងចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មប្រចាំខែ ត្រីមាស ឆមាស ៩ខែដើមឆ្នាំ និងប្រចាំឆ្នាំរបស់កម្ពុជា ។
- ចងក្រង ផ្សព្វផ្សាយ និងណែនាំអនុវត្តដោយឯកភាពនូវចំណាត់ថ្នាក់ ព័ត៌មានស្ថិតិ បណ្តាតារាងគំរូប្រមូលយកព័ត៌មានស្ថិតិពីអង្គភាពរដ្ឋ ឯកជន គ្រឹះស្ថានសាធារណៈនានាសម្រាប់ចងក្រងទិន្នន័យស្ថិតិជាតិ។

**មាត្រា ១៣ : នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច**ទទួលបន្ទុក :

- ប្រមូល ចងក្រងព័ត៌មានបឋមស្តីពីស្ថិតិកសិកម្ម រុក្ខាកម្ម នេសាទ ឧស្សាហកម្ម ពាណិជ្ជកម្ម សំណង់ គមនាគមន៍ ដឹកជញ្ជូន ទេសចរណ៍ និងស្ថិតិបរិស្ថាន ។
- សិក្សា និងសហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំនិងធ្វើជំរឿន អង្កេត ប្រមូលចងក្រង និងវិភាគព័ត៌មានស្ថិតិកសិកម្ម រុក្ខាកម្ម នេសាទ ឧស្សាហកម្ម ពាណិជ្ជកម្ម សំណង់ គមនាគមន៍ ដឹកជញ្ជូន ទេសចរណ៍ និងស្ថិតិបរិស្ថាន ។

**មាត្រា ១៤ : នាយកដ្ឋានស្ថិតិសង្គមកិច្ច**ទទួលបន្ទុក :

- ប្រមូលចងក្រងព័ត៌មានបឋមស្តីពីស្ថិតិសង្គមកិច្ច-ការងារ ស្ថិតិអប់រំសិក្សា ស្ថិតិសុខាភិបាល ស្ថិតិព័ត៌មាន និងស្ថិតិវប្បធម៌ ។
- សិក្សា និងសហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំនិងធ្វើជំរឿន អង្កេតប្រមូលចងក្រង និងវិភាគព័ត៌មានស្ថិតិសង្គមកិច្ច-ការងារ ស្ថិតិអប់រំសិក្សា ស្ថិតិសុខភិបាល ស្ថិតិព័ត៌មាន និងស្ថិតិវប្បធម៌ ។

**មាត្រា ១៥ : នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន អង្កេត** ទទួលបន្ទុក :

- ធ្វើជំរឿន អង្កេត ប្រមូល ចងក្រង និងគ្រប់គ្រងស្ថិតិប្រជាសាស្ត្រ ។

- សហការធ្វើការរៀបចំ អនុវត្តការធ្វើជំរឿន អង្កេតតាមប្រធានបទនានា ក្នុងសំណូមពរ របស់បណ្តាអង្គភាព និងអ្នកប្រើប្រាស់ទិន្នន័យស្ថិតិ ។
- ធ្វើការបណ្តុះបណ្តាលបំពេញសមត្ថភាពជំនាញស្ថិតិ ពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋានតាម តម្រូវការការងារ ។

## ជំពូក ៥

## អគ្គាធិការដ្ឋាន

**មាត្រា ១៦ :អគ្គាធិការដ្ឋាន**របស់ក្រសួងផែនការទទួលបន្ទុក :

- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងផែនការ ។
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះនិងពីមធ្យោបាយកែលម្អការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនេះ ។
- ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ការទុកចិត្ត ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប អមដោយអគ្គាធិការរងមួយ ឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

## ជំពូក ៦

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ១៧ :** ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក ៧

## ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ

**មាត្រា ១៨ : នាយកដ្ឋានរដ្ឋបាលទូទៅ**ទទួលបន្ទុក :

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ ។

- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង។
- តំកល់ឯកសារ និងគ្រប់គ្រងបណ្ណាល័យ។

**មាត្រា ១៩ : នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុទទួលបន្ទុក :**

- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសំភារៈ និងបរិក្ខាររបស់ក្រសួង ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ។
- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង។ ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ទនៈ និងគ្រឿងបន្លាស់ ។
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពខេត្ត ក្រុងនានា។
- កាន់បញ្ជីជាប្រចាំនូវសាលាប័ត្រ និងគណនេយ្យរូបធាតុ។
- ព័ត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី។
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ។
- លើកគម្រោងថវិកាក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ។
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា។
- តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស។
- ប្រមូលផ្តុំ និងសម្របសម្រួលរាល់ចំណាយរបស់ក្រសួង។
- គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តលទ្ធកម្មសាធារណៈ។
- ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់។

**មាត្រា ២០ :នាយកដ្ឋានបុគ្គលិកទទួលបន្ទុក :**

**ក. ក្នុងវិស័យបុគ្គលិក**

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនង នឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំរាល់លិខិតរដ្ឋបាលសម្រាប់ការគ្រប់គ្រងអាជីព ។
- ធ្វើកម្មវិធីតំណែងឯកទេស និង ធនធានមនុស្សរបស់ក្រសួង ។
- វាយតំលៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។

- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខ ងារសាធារណៈ និងអនុវត្តនយោបាយនោះ ។
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងព័ត៌មានប្រតិបត្តិ ។
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

**ខ. ក្នុងវិស័យបណ្តុះបណ្តាល** :មជ្ឈមណ្ឌលបណ្តុះបណ្តាលក្របខ័ណ្ឌផែនការ-ស្ថិតិ ទទួលបន្ទុក :

- រៀបចំការប្រឡងជ្រើសរើសនិងធ្វើការបណ្តុះបណ្តាលនូវមុខវិជ្ជាជំនាញចាំបាច់ក្នុងវិស័យ ផែនការនិងស្ថិតិ
- រៀបចំធ្វើវិក្រឹតការ និងសុក្រឹតការចំពោះមន្ត្រីរាជការរបស់ក្រសួង ។

## ជំពូក ៨

## អង្គភាពមូលដ្ឋាន

**មាត្រា ២១ :** នៅតាមខេត្ត ក្រុងនីមួយៗមានមន្ទីរផែនការខេត្ត ក្រុង ទទួលបន្ទុកអនុវត្ត និងសម្របសម្រួល សកម្មភាព របស់ក្រសួង ។

## ជំពូក ៩

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២២ :** អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមលក្ខខណ្ឌ នៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័ន ត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ១០

## អវសានបញ្ញត្តិ

**មាត្រា ២៣ :** ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋាន ចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ ។

**មាត្រា ២៤:**បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការ ទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ២៦ :** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

**អ៊ឹង ហួត** **ហ៊ុន សែន**

ជម្រាបជូន

- នាយករដ្ឋមន្ត្រីទី ១
- នាយករដ្ឋមន្ត្រីទី ២

រដ្ឋមន្ត្រីក្រសួងផែនការ

**ជា ចាន់តូ**

**<u>ចម្លងជូន</u>**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- គ្រប់ក្រសួងស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ២៥
- ឯកសារ កាលប្បវត្ត

# ឧបសម្ព័ន្ធ ៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៨៥ អនក្រ.បក.**

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានមួយចំនួន ចំណុះវិទ្យាស្ថានជាតិស្ថិតិ

## នៃក្រសួងផែនការ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រេ ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ-បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងផែនការ

- បានឃើញអនុក្រឹត្យ លេខ ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងកិច្ចដំណើរការ របស់ប្រព័ន្ធស្ថិតិជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.-

ត្រូវបានបង្កើតនាយកដ្ឋានស្តង់ដារស្ថិតិនិងវិភាគស្ថិតិ នាយកដ្ឋានបច្ចេកវិទ្យា ទូរគមនាគមន៍ និងព័ត៌មានវិទ្យា នាយកដ្ឋានគណនេយ្យជាតិ និង នាយកដ្ឋានគោលនយោបាយនិងសម្របសម្រួលស្ថិតិ ចំណុះវិទ្យាស្ថានជាតិស្ថិតិ បំពេញបន្ថែម លើអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ ក្រសួងផែនការ ។

## ជំពូកទី ២

## អំពីរចនាសម្ព័ន្ធគ្រប់គ្រង

### មាត្រា ២.-

នាយកដ្ឋាននីមួយៗដែលមានចែងក្នុងមាត្រា ១ ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយដ្ឋានមួយរូប និង អនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានទាំងអស់នេះ ត្រូវកំណត់ដោយប្រកាសរបស់ ក្រសួងផែនការ ។

## ជំពូកទី ៣

## ភារកិច្ច

### មាត្រា ៣.-

នាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- រៀបចំ និងចងក្រងចំណោត់ថ្នាក់ស្ថិតិជាតិ ដើម្បីបម្រើឱ្យការផលិតទិន្នន័យជំរឿន អង្កេត និងការវិភាគ

- រៀបចំ និងចងក្រងទស្សនាទាន និយមន័យស្ថិតិជាតិ

- រៀបចំ និងចងក្រងវិធីសាស្ត្រស្ថិតិរបស់ស្ថិតិផ្លូវការតាមវិស័យ ដើម្បីធានាដំណើរការផលិតទិន្នន័យស្ថិតិផ្លូវការ ឱ្យបានត្រឹមត្រូវ មានគុណភាព និងគួរទុកចិត្តបាន

- សម្របសម្រួលក្នុងការអនុវត្តស្តង់ដារស្ថិតិ និយមន័យស្ថិតិ និងវិធីសាស្ត្រស្ថិតិ ដើម្បីឱ្យអង្គភាពស្ថិតិដែលបានចាត់តាំង អនុវត្តឱ្យបានឯកភាពគ្នា

- វិភាគស៊ីជម្រៅ តាមប្រធានបទដែលបានពីការអង្កេត និងជំរឿន ដូចជា ភាពក្រីក្រ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ការប្រើប្រាស់ពេលវេលា អាហារូបត្ថម្ភ ពលកម្មកុមារ និងប្រធានបទចាំបាច់ផ្សេងទៀត

- ស្រាវជ្រាវ និងចងក្រងព័ត៌មានស្ថិតិសំខាន់ៗតាមសំណូមពរ និងតាមតម្រូវការរបស់អ្នកប្រើប្រាស់ អ្នករៀបចំគោលនយោបាយ និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ តំបន់ និងអន្តរជាតិ

- ផ្សព្វផ្សាយវិធីសាស្ត្រនៃការវិភាគស៊ីជម្រៅ ដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិនៃក្រសួង ស្ថាប័នរាជរដ្ឋាភិបាល

- ទទួលបន្ទុកធ្វើបញ្ជីឈ្មោះទិន្នន័យស្ថិតិរដ្ឋបាល ជំរឿន និងអង្កេត ដែលមានស្រាប់ របស់ក្រសួង ស្ថាប័ន រាជរដ្ឋាភិបាល

- ផ្តល់សេវាកម្មស្រាវជ្រាវ និងវិភាគស្ថិតិ តាមសំណូមពរ និងសេចក្តីត្រូវការរបស់ស្ថាប័នជាតិ តំបន់ និងអន្តរជាតិ ។

## មាត្រា ៩.-

នាយកដ្ឋានបច្ចេកវិទ្យា ទូរគមនាគមន៍ និងព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ដំឡើង កែលម្អ ថែទាំ ជួសជុល ប្រព័ន្ធបណ្តាញកុំព្យូទ័រផ្ទៃក្នុង និងទំនាក់ទំនងបញ្ជូន ព្រមទាំងទទួលព័ត៌មាន និងទិន្នន័យពីក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ដោយធានាផ្តល់នូវសុវត្ថិភាព និងសេវាផ្សេងទៀត ដូចជា អ៊ិនធឺណេត អ៊ីម៉ែល ការរក្សា ការបែងចែកកសារ និងការបោះពុម្ពឯកសារ

- វិភាគតម្រូវការការងារគម្រោង អភិវឌ្ឍប្រព័ន្ធ និងដំឡើងកម្មវិធី ដោយរួមបញ្ចូលទាំង ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ កែតម្រូវបញ្ហា សម្អាតទិន្នន័យ បំប្លែងជាទិន្នន័យមូលដ្ឋាន ព្រមទាំងត្រួតពិនិត្យផ្ទៃកទន់សម្រាប់ការអង្កេត និងជំរឿន

- បង្កើត រៀបចំ ថែរក្សា កែលម្អប្រព័ន្ធ គ្រប់គ្រងទិន្នន័យមូលដ្ឋាន កំណត់លេខកូដ និងអភិវឌ្ឍផ្ទៃកទន់ ដើម្បីអនុវត្តឱ្យមានការឯកភាព និងប្រសិទ្ធភាពនៃទិន្នន័យមូលដ្ឋាន

- បង្កើតរៀបចំវេបសាយ និងប្រព័ន្ធអេឡិចត្រូនិច ដើម្បីផ្សព្វឱ្យផ្សាយអំពីរបាយការណ៍ និងស្ថិតិ

- ទទួលបន្ទុករៀបចំ និងអនុវត្តគោលការណ៍ បែបបទប្រើប្រាស់ និងស្តង់ដារប្រព័ន្ធកុំព្យូទ័រ ដើម្បីធានា ឱ្យមានប្រសិទ្ធភាព និងសុវត្ថិភាព ក្នុងការប្រើប្រាស់ប្រព័ន្ធបណ្តាញកុំព្យូទ័រ និងទិន្នន័យ

- ត្រួតពិនិត្យការវាយបញ្ចូលទិន្នន័យ សម្អាតកំហុសទិន្នន័យបឋម និងធ្វើការណែនាំ ការវាយបញ្ចូលទិន្នន័យដោយកុំព្យូទ័រ

- ផ្តល់ការបណ្តុះបណ្តាលនិងផ្សព្វផ្សាយ ទិន្នន័យមូលដ្ឋាន កម្មវិធីសម្រាប់បញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យ តាមការកំណត់របស់ឯកសារណែនាំ និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទិន្នន័យមូលដ្ឋាន និងព័ត៌មានស្ថិតិ អ្នកប្រើប្រាស់ អ្នកអភិវឌ្ឍផ្នែកទន់ អ្នកប្រើប្រាស់ស្ថិតិនៃក្រសួង ស្ថាប័ន រាជរដ្ឋាភិបាលកម្ពុជា និងសាធារណជន

- ស្រាវជ្រាវ និងដាក់ឱ្យប្រើប្រាស់ បច្ចេកវិទ្យាកុំព្យូទ័រថ្មីៗ ក្នុងក្រសួង ដែលទាក់ទងនឹង ការគ្រប់គ្រងប្រព័ន្ធបណ្តាញកុំព្យូទ័រ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ការវិភាគ និងគ្រោង ការវាយបញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យ អ៊ិនធឺណែត អ៊ីម៉ែល វេបសាយ ។

## មាត្រា ៥.-

នាយកដ្ឋានគណនេយ្យជាតិ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ប៉ាន់ស្មាន និងវិភាគស្ថិតិម៉ាក្រូសេដ្ឋកិច្ច ក្រោមការគ្រប់គ្រងនៃវិទ្យាស្ថានជាតិស្ថិតិ

- ធ្វើរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ចជាតិ ការវិវត្តតាមវិស័យ អតិផរណា និងសន្ទស្សន៍ថ្លៃផ្សេងទៀត

- ចងក្រង វិភាគ និងបោះផ្សាយស្ថិតិគណនេយ្យជាតិ គណនីស្ថាប័ន គណនីលំហូរ គណនីចំណាយ គណនីមូលធន គណនីហិរញ្ញវត្ថុ គណនីពាណិជ្ជកម្មអន្តរជាតិ តារាងផ្គត់ផ្គង់និងតារាងតម្រូវការ តារាងលំហូរគណនីចូល និងលំហូរគណនីចេញ តាមប្រព័ន្ធគណនេយ្យជាតិ តាមថ្លៃថេរ និងថ្លៃបច្ចុប្បន្ន ប្រចាំឆ្នាំ

- ចងក្រង វិភាគ និងបោះពុម្ពផ្សាយ ស្ថិតិគណនេយ្យជាតិ តាមវិស័យផលិតកម្ម និងចំណាយតាមថ្លៃថេរ និងថ្លៃបច្ចុប្បន្ន ប្រចាំត្រីមាស

- អង្កេត ចងក្រង វិភាគ និងបោះពុម្ពផ្សាយ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំត្រីមាស សន្ទស្សន៍ថ្លៃនាំចេញ នាំចូល ប្រចាំត្រីមាស សន្ទស្សន៍ថ្លៃកសិកម្មប្រចាំត្រីមាស និងសន្ទសសន៍ថ្លៃផ្សេងទៀត

- ប្រមូល និងចងក្រង ទិន្នន័យរដ្ឋបាល តាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដើម្បីគាំទ្រការប៉ាន់ស្មានទិន្នផលស្ថិតិតាមវិស័យ និងគណនេយ្យជាតិប្រចាំត្រីមាស និងប្រចាំឆ្នាំ

- អង្កេត និងចងក្រង សូចនាករសេដ្ឋកិច្ចមួយចំនួន ដើម្បីធានាគុណភាពនៃការប៉ាន់ស្មានស្ថិតិគណនេយ្យជាតិ

- រៀបចំ និងធ្វើឱ្យប្រសើរឡើងនូវ វិធីសាស្ត្រប៉ាន់ស្មានគណនី និងអនុវត្តពេញលេញ តាមប្រព័ន្ធគណនេយ្យជាតិ នៃអង្គការសហប្រជាជាតិ

- រៀបចំ និងចងក្រង សៀវភៅណែនាំស្តីពី ប្រព័ន្ធគណនេយ្យជាតិ និងស្ថិតិថ្លៃ ។

## មាត្រា ៦.-

នាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិ មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- រៀបចំគោលនយោបាយ ក្នុងការពង្រឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ ដែលបានចាត់តាំង
- រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រឹងប្រព័ន្ធស្ថិតិជាតិ និងកិច្ចសហប្រតិបត្តិការស្ថិតិ
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ដល់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គភាពឯកជន និងសាធារណៈជន ឱ្យបានដឹងអំពីសារៈសំខាន់នៃស្ថិតិ
- រកដំណោះស្រាយក្នុងករណីមានបទល្មើសស្ថិតិជាតិ
- សហប្រតិបត្តិការស្ថិតិទ្វេភាគី ពហុភាគីក្នុងតំបន់ លើពិភពលោក និងសម្របសម្រួលការងារសម្រាប់អ្នកស្រាវជ្រាវស្ថិតិអន្តរជាតិ
- សហការជាមួយស្ថាប័នជាតិ តំបន់ និងអន្តរជាតិដើម្បីផ្តល់ទិន្នន័យ និងសេវាកម្មស្ថិតិ
- គ្រប់គ្រងធនធានមនុស្ស និងបណ្តុះបណ្តាលជំនាញស្ថិតិ ដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីស្ថិតិក្រសួង ស្ថាប័នរាជរដ្ឋាភិបាល
- បូកសរុបសកម្មភាពការងារ និងធ្វើរបាយការណ៍តាមកាលកំណត់ស្តីពីការអនុវត្តការងារស្ថិតិ របស់វិទ្យាស្ថានជាតិស្ថិតិ
- គ្រប់គ្រងលិខិតស្នាម និងតម្កល់ឯកសារ
- រៀបចំ និងគ្រប់គ្រងការងារចុះធ្វើសម្ភាសន៍ និងប្រមូលទិន្នន័យស្ថិតិ
- រៀបចំផែនការយុទ្ធសាស្ត្រសកម្មភាពការងារស្ថិតិរយៈពេលខ្លី មធ្យម និងវែង
- ធ្វើគម្រោងថវិកាសម្រាប់ដំណើរការការងារស្ថិតិប្រចាំឆ្នាំ រយៈពេលខ្លី មធ្យម និងវែង របស់វិទ្យាស្ថានជាតិស្ថិតិ
- ធ្វើជាលេខាធិការដ្ឋានជូនគណៈកម្មាធិការសម្របសម្រួល ។

## ជំពូកទី ៤
## អវសានបទប្បញ្ញត្តិ

### មាត្រា ៧.-

មាត្រា ១២ ស្តីពីនាយកដ្ឋានស្ថិតិទូទៅនៃអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

### មាត្រា ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកស្តីទីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**ទីកន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៤

# ពាក្យបំព្រួញ

| | |
|---|---|
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ផ.យ.ផ.ក. | ផែនការយុទ្ធសាស្ត្រក្រសួងផែនការ |
| គ.អ.ស.ក | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| ក.វ.ស. | កម្មវិធីវិនិយោគសាធារណៈ |